00189485

០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០៣)

E22/I/35

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

| | |
|---|---|
| សំណុំរឿងព្រហ្មទណ្ឌលេខ: | ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០៣) |
| បញ្ជូនទៅ: | អង្គបុរេជំនុំជម្រះ |
| កាលបរិច្ឆេទនៃការបញ្ជូន: | ១៩ ឧសភា ២០០៨ |
| ភាគីបញ្ជូន: | សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី |
| ភាសាដើម: | ខ្មែរ និងអង់គ្លេស |
| ប្រភេទឯកសារ: | សាធារណៈ |

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 20 / 05 / 2008
ម៉ោង (Time/Heure): 10h50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CHEA K.

**សារណាតបរួមរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី នៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន**

**បញ្ជូនដោយ :**

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

លោកមេធាវី ហុង គឹមសួន

លោកមេធាវី ឡោ ជុនធី

លោកមេធាវី នី ចាន់ឌី

លោកមេធាវី គង់ ពិសី

លោកស្រីមេធាវី Silke Studzinsky

**ចែកចាយជូន :**

**អង្គបុរេជំនុំជម្រះ**

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម Rowan DOWNING

ចៅក្រម ន៉យ ថុល

ចៅក្រម Katinka LAHUIS

ចៅក្រម ហួត វុទ្ធី

**សហមេធាវីការពារអៀង សារី**

លោកមេធាវី អាង ឧត្តម

លោកមេធាវី Michael G. Karnavas

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Robert PETIT

**ឯកសារបានចំលងចេញត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 20 / 05 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

## I- សាវតានីតិវិធី

១. នៅថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ការិយាល័យសហចៅក្រមស៊ើបអង្កេត (ហៅថា ក.ស.ច.ស) បានចេញដីកាឃុំខ្លួនបណ្តោះអាសន្ន[១] ។

២. នៅថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៨ សហមេធាវីរបស់ជនត្រូវចោទបានប្តឹងឧទ្ធរណ៍[២] ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ននេះ ហើយបានពិភាក្សាតែទៅលើលទ្ធផលរកឃើញរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ដោយអនុលោមតាមវិធាន ៦៣ (៣) ចំនុច (ក) និង (ខ) ។

៣. នៅថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០៨[៣] អង្គបុរេជំនុំជម្រះ (ហៅថា អ.ប.ជ) បានបង្គាប់ជនត្រូវចោទតាមរយៈសហមេធាវីឱ្យដាក់សារណាទៅនឹងបញ្ហាយុត្តាធិការដែលលើកឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេតនៅក្នុងវាក្យខ័ណ្ឌពីទី៩ ដល់ ទី១៤ នៃដីកាឃុំខ្លួនបណ្តោះអាសន្ន[៤] ។

៤. នៅថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៨ មេធាវីការពារបានដាក់ "សារណាដែលមានកាលកំណត់របស់ អៀង សារី ស្តីពីយុត្តាធិការ"[៥] (ហៅថាសារណា) ។

៥. អង្គបុរេជំនុំជម្រះបានបង្គាប់[៦] មកមេធាវីដើមបណ្តឹងរដ្ឋប្បវេណីដាក់ចម្លើយតបរបស់ខ្លួនក្នុងរយៈពេល ១៥ ថ្ងៃ បន្ទាប់ពីការជូនដំណឹងនៃដីកានេះ។ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានទទួលដីកានេះ

---

[១] ករណី អៀង សារី សំណុំរឿងលេខ ០០២/១៩-០៩-២០០៧ អ.វ.ត.ក/ក.ស.ច.ស ដីកាឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៤ វិច្ឆិកា ២០០៧ ឯកសារតុលាការលេខ C២២

[២] ករណី អៀង សារី សំណុំរឿងលេខ ០០២/១៩-០៩-២០០៧ អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០៣) បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៥ មករា ២០០៨ ERN00១៥៩០២៥ ឯកសារតុលាការលេខ C២២/I/៥

[៣] ករណី អៀង សារី សំណុំរឿងលេខ ០០២/១៩-០៩-២០០៧ អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០៣) សេចក្តីសំរេចស្តីពី សំណើសុំជំរុញនីតិវិធីឱ្យលឿនរបស់សហមេធាវីអៀង សារី ចំពោះការពន្យារពេលវេលាដ៏សមហេតុផលដើម្បីដាក់ការជំទាស់ទៅនឹងបញ្ហាយុត្តាធិការ ចុះថ្ងៃទី ៣ មីនា ២០០៨ ERN 00១៦៥៣០៥-00១៦៥៣០៧

[៤] ចូរមើល supra កំណត់សំគាល់ ១

[៥] ករណី អៀង សារី សំណុំរឿងលេខ ០០២/១៩-០៩-២០០៧ អ.វ.ត.ក/កស.ច.ស (អ.ប.ជ ០៣) សារណា អៀង សារី អនុលោមតាមសេចក្តីសម្រេចស្តីពី សំណើសុំជំរុញនីតិវិធីឱ្យលឿនរបស់សហមេធាវី ចំពោះការពន្យាពេលវេលាដ៏សមហេតុផលដើម្បីដាក់ការជំទាស់ទៅនឹងបញ្ហាយុត្តាធិការ ERN 00១៧៧២៦៥-00១៧៧២៨០

[៦] ករណីលោក អៀង សារី, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧ អ.វ.ត.ក/កស.ច.ស (អ.ប.ជ ០៣), ដីកាណែនាំឱ្យដើមបណ្តឹងរដ្ឋប្បវេណីដាក់សារណាជាលាយលក្ខណ៍អក្សរ, ចុះថ្ងៃទី ៣០ មេសា ២០០៨, ERN00១៨៤៩៧៥ ឯកសារលេខ C២២/I/៣០

00189487



នៅថ្ងៃទី ៣០ មេសា ឆ្នាំ ២០០៨។ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី សូមភ្ជាប់ជាមួយនូវសារណាតបរួមមួយទៅនឹងបណ្តឹងឧទ្ធរណ៍នេះ។

## II. សង្ខេបនត្តីករណ៍

៦. គោលការណ៍អំពីការជំនុំជម្រះតែមួយលើក មិនអនុវត្តចំពោះការផ្តន្ទាទោសដោយតុលាការប្រជាជនបដិវត្តន៍កម្ពុជាចុះថ្ងៃទី ១៩ សីហា ឆ្នាំ ១៩៧៩ ទេ ដោយសារនីតិវិធីនៃតុលាការនេះមិនបានប្រព្រឹត្តទៅ (ក) ដោយឯករាជ្យ, (ខ) ដោយអព្យាក្រឹត, (គ) ហើយមិនស្របតាមបទដ្ឋានអន្តរជាតិ។ ដូចនៅក្នុងសារណាបង្ហាញឱ្យឃើញថាវាគ្រប់គ្រាន់រួចទៅហើយដើម្បីឆ្លើយតបតែកត្តាមួយក្នុងចំណោមកត្តាទាំងនេះដើម្បីបង្កើតអញ្ញត្រកម្មមួយពីគោលការណ៍អំពីការជំនុំជម្រះតែមួយលើក។ ការអនុវត្តឱ្យស្របតាមបទដ្ឋានអន្តរជាតិ គឺជាតំលៃមួយដ៏ត្រឹមត្រូវ និងជាការការពារចំពោះជនត្រូវចោទ ឬ ទណ្ឌិត ទោះបីជាគេមិនបានបង្ហាញភស្តុតាងឱ្យឃើញថាការកាត់ទោសនៅឆ្នាំ ១៩៧៩ ត្រូវបានរៀបចំឡើងដើម្បីបិទបាំងជនត្រូវចោទឱ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌក៏ដោយ។

៧. ឆ្នាំ១៩៩៦ ពិតជាមានការប្រទានការលើកលែងទោសឬការលើកលែងទោសជាទូទៅដោយព្រះមហាក្សត្រមែនប៉ុន្តែវាមិនចងភ្ជាប់កាតព្វកិច្ច អ.វ.ត.ក ទេ។ យោងតាមរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាមាត្រា២៧ គ្រាន់តែចែងថាព្រះមហាក្សត្រមានព្រះរាជសិទ្ធិលើកលែងទោស។ ព្រះមហាក្សត្រទ្រង់បានប្រើព្រះរាជសិទ្ធិលើស ដោយចេញការលើកលែងទោសជាទូទៅសំរាប់ការកាត់ទោសនៅពេលខាងមុខតាមច្បាប់ឆ្នាំ ១៩៩៤ ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់។ ព្រះមហាក្សត្រទ្រង់មានតែព្រះរាជសិទ្ធិលើកលែងទោសចំពោះទណ្ឌិតជាការប្រោសប្រណីទោសប៉ុណ្ណោះ ដូច្នេះការលើកលែងទោសដែលធ្វើឡើងនៅឆ្នាំ ១៩៩៦ គឺមិនស្របតាមបទដ្ឋានអន្តរជាតិហើយក៏មិនចងកាតព្វកិច្ចសាលាក្តី អ.វ.ត.ក ដែរ។

៨. ឆន្ទានុសិទ្ធិរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតត្រូវគេបានអនុវត្តយ៉ាងត្រឹមត្រូវ ហើយបង្ហាញថាមានមូលដ្ឋានសមហេតុផលនិង រឹងមាំ។ បណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តីមិនបានបង្ហាញឱ្យឃើញថាមានកំហុសឆ្គងនៅក្នុងដីកាឃុំខ្លួននោះទេ។

អនុលោមតាមវិធាន៦៣ (៣) ចំនុច (ក) មានមូលហេតុដែលត្រូវបានគេរកឃើញ និងជឿជាក់យ៉ាងច្បាស់ថាជននោះធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬ ច្រើន ដូចមានចែងលំអិតនៅក្នុងដីកាសន្និដ្ឋាន

បញ្ជូនរឿងឱ្យស៊ើបសួរ។ លើសពីនេះទៅទៀត ដីកាឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានការដ៏ចំបាច់ដើម្បីរារាំងកុំឱ្យជនត្រូវចោទគាបសង្កត់ទៅលើសាក្សី ឬ ជនរងគ្រោះ រក្សាសណ្តាប់ធ្នាប់សាធារណៈ ការពារសុវត្ថិភាពខ្លួនគាត់និងធានាវត្តមានរបស់ជនត្រូវចោទនៅក្នុងការជំនុំជម្រះនាពេលខាងមុខ។ ដីកានេះស្របទៅនឹងលក្ខខណ្ឌនៃវិធាន ៦៣ (៣) ចំនុច (ខ)ពីលេខ ១ ដល់ ៥។

## III. អង្គហេតុពាក់ព័ន្ធ

៩. នៅថ្ងៃទី ១៩ សីហា ១៩៧៩ បន្ទាប់ពីការជំនុំជម្រះរយៈពេល៥ថ្ងៃ ជនត្រូវចោទត្រូវគេផ្តន្ទាទោស និងកាត់ទោសប្រហារជីវិតពីបទប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ដោយតុលាការបដិវត្តន៍ប្រជាជនកម្ពុជា[៧] (ការជំនុំជម្រះឆ្នាំ១៩៧៩)។ ទ្រព្យសម្បត្តិរបស់ជនត្រូវចោទត្រូវបានរឹបអូស ប៉ុន្តែជនត្រូវចោទមិនដែលត្រូវគេចាប់ខ្លួនពីបទជាប់ពាក់ព័ន្ធទៅនឹងនីតិវិធីទាំងនេះទេ។ ការជំនុំជម្រះធ្វើឡើងដោយកំបាំងមុខ។ ការជំនុំជម្រះនេះផ្អែកលើក្រិត្យច្បាប់លេខ ១ ចុះថ្ងៃទី ១៥ កក្កដា ១៩៧៩[៨]។ ការចោទប្រកាន់នេះចុះការបរិច្ឆេទថ្ងៃទី ០១ សីហា ១៩៧៩[៩]។

១០. នៅថ្ងៃទី ៧ កក្កដា ១៩៩៤ រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា បានអនុម័ត "ច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់"[១០]។ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាល ច្បាប់នេះបានទុករយៈពេល ៦ខែ ដើម្បីលើកលែងទោសជាទូទៅ ចំពោះអ្នកដែលបានធ្វើសមាហរណកម្ម

---

[៧] សាលក្រមរបស់តុលាការប្រជាជនបដិវត្តន៍កម្ពុជា ចុះថ្ងៃទី ១៩ សីហា ១៩៧៩ U.N.A/៣៤/៤៩១ បានបោះពុម្ពផ្សាយជាថ្មី នៅក្នុងលិខិតចុះថ្ងៃទី ១៧ កញ្ញា ១៩៧៩ ដកស្រង់ចេញពីអ្នកតំណាងអចិន្ត្រៃយ៍របស់ប្រទេសវៀតណាមប្រចាំនៅ អ.ស.ប បានចារទៅអគ្គលេខាអ.ស.ប

[៨] Howard J. De Nike, John Quigley and Kenneth J. Robinson ប្រល័យពូជសាសន៍ក្នុងប្រទេសកម្ពុជា ឯកសារពីការជំនុំជម្រះរបស់ ប៉ុល ពត និង អៀង សារី Philadelphia Pennsylvania 2000 ទំព័រពីទី៤៥ ដល់ ទី៤៧

ក្រិត្រច្បាប់នេះបានកំនត់និយមន័យនៃបទឧក្រិដ្ឋប្រល័យពូជសាសន៍មានលក្ខណៈពិសេសមួយ ដើម្បីធ្វើឱ្យត្រូវនឹងស្ថានភាពហេតុការណ៍ជាក់លាក់ ដែលកំណត់និយមន័យនៃបទឧក្រិដ្ឋប្រល័យពូជសាសន៍ថាជាៈ ការសម្លាប់រង្គាលនូវប្រជាជនស្លូតត្រង់ដោយមានគំរោងផែនការបណ្តេញប្រជាជនឱ្យចេញផុតពីទីក្រុង ភូមិករ ដើម្បីយកទៅប្រមូលផ្តុំ ហើយបង្ខំឱ្យគេធ្វើការបាក់កម្លាំង ក្នុងលក្ខណៈប្រល័យកំទេចទាំងខាងរូបកាយទាំងខាងស្មារតី របស់គេទាំងនោះ កំទេចសាសនា កំទេចរចនាសម្ព័ន្ធសេដ្ឋកិច្ច វប្បធម៌ និងទំនាក់ទំនងផ្សេងៗក្នុងគ្រួសារ និងសង្គម។

[៩] ចូរមើល Supra 8 ទំព័រ ៥២៤

[១០] កំរងឯកសារច្បាប់ដែលនៅជាធរមាននាពេលបច្ចុប្បន្ននៅក្នុងព្រះរាជាណាចក្រកម្ពុជា ការបកប្រែមិនផ្លូវការ អ.ស.ប. ចុះខែ មករា ២០០២. ពីទំព័រទី៨៣៦ ដល់ទី៨៣៩។

ចូលព្រះរាជាណាចក្រកម្ពុជាដើម្បីបញ្ចប់សង្គ្រាមដែលកំពុងបន្ត[១១] ។ ក្នុងមាត្រា៦ នៃច្បាប់នេះ មេដឹកនាំនៃក្រុម "កម្ពុជាប្រជាធិបតេយ្យ" ច្បាស់ណាស់មិនត្រូវគេរាប់បញ្ចូលពីការលើកលែងទោសនេះឡើយ ។

១១. នៅថ្ងៃទី១៤ កញ្ញា ១៩៩៦ ព្រះមហាក្សត្រប្រសប្រទានការលើកលែងទោសដល់ជនត្រូវចោទចំពោះការកាត់ទោសនៅឆ្នាំ១៩៧៩ដោយប្រហារជីវិត និងការរឹបអូសយកទ្រព្យសម្បត្តិទាំងអស់ ព្រមទាំងការលើកលែងទោសទូទៅចំពោះការកាត់សេចក្តីនាពេលខាងមុខ តាមច្បាប់ស្តីពី "ការដាក់ក្រុមកម្ពុជាប្រជាធិបធិបតេយ្យឱ្យនៅក្រៅច្បាប់"[១២] ។

១២. នៅថ្ងៃទី០៦ មិថុនា ២០០៣ អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាបានចុះកិច្ចព្រមព្រៀង[១៣] មួយក្នុងគោលបំណង "ដើម្បីនាំមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតក្នុងរបបកម្ពុជាប្រជាធិបតេយ្យមកកាត់ទោសចំពោះរាល់បទឧក្រិដ្ឋ និងការរំលោភធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជាច្បាប់មនុស្សធម៌និងទំនៀមទំលាប់អន្តរជាតិ និងអនុសញ្ញាអន្តរជាតិទាំងឡាយ ដែលប្រទេសកម្ពុជាបានទទួលស្គាល់ ដែលបានប្រព្រឹត្តក្នុងអំឡុងពេលពីថ្ងៃទី ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ទី ០៦ មករា ១៩៧៩" ។ ការអនុវត្តកិច្ចព្រមព្រៀងក្រោយមកទៀតនៅក្នុងច្បាប់អ.វ.ត.ក[១៤] និយាយយោងទៅរកគោលបំណងដូចគ្នាអញ្ចឹងដែរ ។ ដូច្នេះគេត្រូវបើកការស៊ើបអង្កេតនៃបទឧក្រិដ្ឋ ដែលបានប្រព្រឹត្តនេះ ។ កិច្ចព្រមព្រៀង និងច្បាប់អ.វ.ត.ក បានកំនត់ថា វិសាលភាពនៃការលើកលែងទោសចុះថ្ងៃទី១៤ កញ្ញា ឆ្នាំ១៩៩៦ ឬក៏មុនពេលការអនុម័តនៃច្បាប់អ.វ.ត.ក " គឺជាបញ្ហាមួយដែលត្រូវធ្វើការសម្រេចដោយអង្គជំនុំជម្រះវិសាមញ្ញ"[១៥] ។

---

១១ មាត្រា ៥ នៃច្បាប់ដែលបានលើកឡើងខាងលើ.កំណត់សំគាល់ supra 10

១២ ព្រះរាជក្រិត្រ. នស/ព្រះរាជក្រិត្រ/០៩៦៦/៧២ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១ នស ៩៤ ចុះថ្ងៃទី ១៤

១៣ កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវបទឧក្រិដ្ឋដែលប្រព្រឹត្តនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ មាត្រា ១

១៤ ច្បាប់ស្តីពី ការបង្កើតអ.វ.ត.កដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មក្នុងរយៈកាលនៃ កម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ១០ សីហា ២០០១ នស/ព្រះរាជក្រម /០៨០១/១២ បានធ្វើវិសោធនកម្មថ្ងៃទី ២៧ តុលា ២០០៤ បទបញ្ញត្តិទូទៅ ជំពូក ១ មាត្រា ១

១៥ មាត្រា ១១ នៃកិច្ចព្រមព្រៀង កំណត់សំគាល់ supra លេខ ១៣ និងមាត្រា ៤០ នៃច្បាប់ អ.វ.ត.ក កំណត់សំគាល់ supra លេខ ១៤

## IV- គោលការណ៍អំពីការជំនុំជម្រះតែមួយលើក

### ក- មូលដ្ឋានច្បាប់

១៣. មាត្រា ១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា[១៦] ចែងថា "អាជ្ញាអស់ជំនុំ ដោយអនុវត្តតាមគោលការណ៍អំពីការជំនុំជម្រះតែមួយលើក ជនណាដែលត្រូវបានតុលាការសម្រេចឱ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចត្រូវចោទប្រកាន់ទៀតទេចំពោះអំពើដដែល ទោះបីជាក្រោមការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងក៏ដោយ" ។

រហូតមកទល់ពេលនេះក្រមនីតិវិធីព្រហ្មទណ្ឌ បង្ហាញនូវភាពចន្លោះប្រហោងដោយសារគោលការណ៍អំពីការជំនុំជម្រះតែមួយលើកមិនមែនជាលក្ខខ័ណ្ឌដាច់ខាតនោះទេ ហើយក្នុងក្រមនេះមិនបានចែងអំពី ករណីអញ្ញត្រកម្មនៃគោលការណ៍នេះដែរ ។ ដូច្នេះគេត្រូវស្វែងរកការណែនាំក្នុងបទដ្ឋានច្បាប់អន្តរជាតិដែលបានលើកឡើងអំពីគោលការណ៍នេះ ។

១៤. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ហៅថា ICCPR)[១៧] ចែងក្នុងមាត្រា ១៤ ចំនុច(៧) ថា "គ្មានជនណាម្នាក់ត្រូវយកមកចោទប្រកាន់ ឬយកមកផ្តន្ទាទោសសារជាថ្មីឡើយចំពោះបទល្មើស ដែលបានផ្តន្ទាទោសជាស្ថាពរ ឬបានសំរេចឱ្យរួចខ្លួនស្របតាមច្បាប់ និងនីតិវិធីព្រហ្មទណ្ឌរបស់រដ្ឋនីមួយៗរួចហើយ ។

១៥. ច្បាប់លក្ខន្តិកៈនៃសាលាក្តីព្រហ្មទណ្ឌអន្តរជាតិសំរាប់អតីតយូហ្គោស្លាវី[១៨] ចែងថា :

**មាត្រា ១០ :** អំពីការជំនុំជម្រះតែមួយលើក

(១) - គ្មានជនណាម្នាក់នឹងត្រូវបានគេយកមកកាត់ទោសនៅតុលាការជាតិ ចំពោះអំពើទាំងឡាយណាដែលត្រូវចោទប្រកាន់ពីបទរំលោភដ៏ធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិដែលមានចែងនៅក្នុងលក្ខន្តិកៈបច្ចុប្បន្ន ហើយដែលជនត្រូវចោទនោះត្រូវបានកាត់ទោសរួចហើយនៅតុលាការអន្តរជាតិ ។

---

[១៦] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, ចុះថ្ងៃទី ១០ សីហា ២០០៧, មាត្រា ១២

[១៧] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, ចុះថ្ងៃ ១៦ ធ្នូ ១៩៦៦, វេបសាយ: www.ochr.org

[១៨] ច្បាប់លក្ខន្តិកៈនៃសាលាក្តីព្រហ្មទណ្ឌអន្តរជាតិសំរាប់រ្វ៉ាន់ដា ("ICTR") មាត្រា ១៩ ហើយដូចគ្នាអញ្ចឹងដែរនៅក្នុងច្បាប់លក្ខន្តិកៈនៃសាលាក្តីព្រហ្មទណ្ឌអន្តរជាតិអតីតយូហ្គោស្លាវី ("SCSL") មាត្រា ៩ ចែងអំពីគោលការណ៍ជំនុំជម្រះតែមួយលើក ដែលប្រើពាក្យដូចគ្នាទៅនិងច្បាប់លក្ខន្តិកៈរបស់ ("ICTY")

00189491



C22/5/35

(២) - ជនណាដែលត្រូវបានគេយកមកកាត់ទោសនៅតុលាការជាតិរួចហើយ ចំពោះអំពើទាំងឡាយណាដែលរំលោភដ៏ធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ ក្រោយមកជននោះអាចត្រូវបានយកមកជំនុំជម្រះឡើងវិញបានដោយតុលាការអន្តរជាតិក្នុងករណី :

(ក). អំពើដែលគេជំនុំជម្រះជននោះត្រូវគេចាត់ទុកថាជាបទឧក្រិដ្ឋធម្មតា ឬ

(ខ). នីតិវិធីនៅតុលាការជាតិ ប្រព្រឹត្តទៅដោយលំអៀង ឬមិនឯករាជ្យ ហើយរៀបចំឡើងដើម្បីបិទបាំងជនត្រូវចោទឱ្យរួចផុតចំពោះឧក្រិដ្ឋកម្មអន្តរជាតិ ឬរឿងក្តីនោះត្រូវគេកាត់ក្តីដោយមិនយកចិត្តទុកដាក់ ។[១៩]

១៦. ច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ មាត្រា ២០ អំពីការជំនុំជម្រះតែមួយលើក (Ne bis in idem) ចែងថា :

១. លើកលែងតែមានចែងក្នុងច្បាប់លក្ខន្តិកៈនេះ គ្មានជនណាម្នាក់ត្រូវបានជំនុំជម្រះដោយតុលាការទាក់ទងលើការប្រព្រឹត្តដែលបានបង្កើតជាមូលដ្ឋាននៃបទល្មើសព្រហ្មទណ្ឌដែលជននោះត្រូវបានតុលាការសំរេចឱ្យមានពិរុទ្ធភាព(ឱ្យមានទោស) ឬសំរេចឱ្យរួចខ្លួន (គ្មានទោស)ម្តងរួចទៅហើយនោះទេ ។

២. គ្មានជនណាម្នាក់ត្រូវជំនុំជម្រះនៅក្នុងតុលាការមួយទៀត ចំពោះបទល្មើសព្រហ្មទណ្ឌដែលបានចែងនៅក្នុងមាត្រា៥ ដោយជននោះត្រូវបានតុលាការសំរេចឱ្យមានពិរុទ្ធភាព ឬគ្មានពិរុទ្ធភាពរួចទៅហើយនោះទេ ។

៣. គ្មានជនណាម្នាក់ ដែលត្រូវបានជំនុំជម្រះដោយតុលាការមួយផ្សេងទៀតចំពោះការប្រព្រឹត្តដែលបានពណ៌នាផងដែរនៅក្នុងមាត្រា ៦, ៧ ឬ ៨ ត្រូវជំនុំជម្រះដោយតុលាការទាក់ទងទៅលើការប្រព្រឹត្តដូចគ្នាតែមួយទេ លើកលែងតែដំណើរការទាំងឡាយនៅក្នុងតុលាការមួយផ្សេងទៀតនោះ:

(ក). ត្រូវបានធ្វើឡើងសំរាប់គោលបំណងលាក់បាំងជនដែលពាក់ព័ន្ធ ពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌ សំរាប់បទល្មើសដែលឋិតនៅក្នុងយុត្តាធិការនៃតុលាការនោះ ។ ឬ

(ខ). បើមិនអញ្ចឹងទេ ត្រូវបានធ្វើឡើងដោយគ្មានឯករាជ្យ ឬ ដោយគ្មានភាពឥតលំអៀងស្របតាមបទដ្ឋាននៃដំណើរនីតិវិធីដែលទទួលស្គាល់ដោយច្បាប់អន្តរជាតិហើយ ត្រូវបានធ្វើឡើង

---

[១៩] ការគូសបញ្ជាក់បន្ថែម

តាមរបៀបមួយដែលក្នុងកាលៈទេសៈនានា មិនស្របតាមចេតនានាំខ្លួនជនដែលពាក់ព័ន្ធនោះមករកយុត្តិធម៌[២០] ។

**ខ. ការពិភាក្សា**

១៧. គោលការណ៍អំពីការជំនុំជម្រះតែមួយលើកនេះ[២១] ត្រូវគេទទួលស្គាល់ជាលក្ខណៈអន្តរជាតិយ៉ាងទូលំទូលាយ ប៉ុន្តែគោលការណ៍នេះត្រូវកំណត់ជាពិសេសត្រឹមកំរិតថ្នាក់ជាតិ ។ ដោយបង្កើតឱ្យមានសាលាក្តីអន្តរជាតិពិសេស និងតុលាការព្រហ្មទណ្ឌអន្តរជាតិ ការមិនអនុវត្តតាមទំលៀមទំលាប់នៅកំរិតអន្តរជាតិត្រូវបានគេកំពុងចោទជាសំណួរ ។

ទោះបីជាយ៉ាងណាក៏ដោយការកាត់ទោសដែលធ្វើឡើងនៅឆ្នាំ១៩៧៩ គឺមិនមែនជាការកាត់ទោសលក្ខណៈជាអន្តរជាតិទេ វាគ្រាន់តែជាសេចក្តីសំរេចដោយកម្ពុជាតែឯង ។

ដើម្បីធ្វើការបកស្រាយគោលការណ៍អំពីការជំនុំជម្រះតែមួយលើក និងអញ្ញត្រកម្មដែលគេទទួលស្គាល់ជាលក្ខណៈអន្តរជាតិរបស់គោលការណ៍នេះ ច្បាប់លក្ខន្តិកៈនៃសាលាក្តីអន្តរជាតិគួរយកមកពិចារណា ។

---

២០ ការគួសបញ្ជាក់បន្ថែម

២១ សន្ធិសញ្ញាជា"សកល" (គឺថា មិនមែនមានត្រឹមតែនៅទ្វីបអ៊ឺរ៉ុបទេ) ជាឧទាហរណ៍ សុពលភាពអនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស O.A.S Treaty Series លេខ ៣៦ ១៤៤.U.N.T.S ១២៣ មាត្រា ៨ កថាខ័ណ្ឌ ៤ វិធានអប្បរមាបទដ្ឋាន អ.ស.ប សំរាប់ការព្យាបាលអ្នកទោស (វិធាន ៣០ ចំនុចទី ១) អនុសញ្ញាជាសកលស្តីពីការបោះពុម្ពផ្សាយរឿងអាសអាភាស ( មាត្រា ២ កថាខ័ណ្ឌ២)

និងអនុសញ្ញាពិសេសស្តីពីគ្រឿងញៀន ឆ្នាំ១៩៦១ ( មាត្រា ៣៦-២-ក-IV-)) ជាងនេះទៅទៀតគោលការណ៍នេះឃើញមាននៅក្នុងក្រម ឬធម្មនុញ្ញជាតិជាច្រើន ។

អនុសញ្ញា Schengen អ៊ឺរ៉ុប ចែងក្នុងមាត្រា ៥៤ថា "ជនណាដែលត្រូវគេវិនិច្ឆ័យទោសជាស្ថាពរដោយភាគីហត្ថលេខី មិនអាចត្រូវគេកាត់ទោសដោយភាគីហត្ថលេខីមួយទៀតបានទេចំពោះបទល្មើសដដែល ដោយហេតុថាជនត្រូវចោទនោះត្រូវបានកាត់ទោសរួចហើយ ឬ អនុវត្តទោសរួចហើយ ឬកំពុងអនុវត្តទោស ឬគេអាចលែងអនុវត្តតាមច្បាប់ដែលគេកាត់ទោសនៃរដ្ឋហត្ថលេខីទៀតទេ" ។

តុលាការយុត្តិធម៌អ៊ឺរ៉ុបបានលើកឡើងនៅក្នុងសេចក្តីសម្រេច Hüseyin Gözütök and Klaus Brügge ចុះថ្ងៃទី ១១ កុម្ភៈ ឆ្នាំ២០០៣ រឿងក្តីរួមគ្នា C-១៨៧/០១ a. C-៣៨៥/០១ ថាមិនមានការជាប់ទាក់ទងដ៏ចំបាច់ ដែលថារដ្ឋជាសមាជិកត្រូវមានការទុកចិត្តគ្នាទៅវិញទៅមកនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌរបស់ពួកគេ ហើយថារដ្ឋជាសមាជិកនីមួយៗត្រូវទទួលស្គាល់ច្បាប់ព្រហ្មទណ្ឌដែលនៅជាធរមាននៅក្នុងបណ្តារដ្ឋជាសមាជិកដ៏ទៀត ទោះបីជាលទ្ធផលខុសគ្នាក៏ដោយ ប្រសិនបើច្បាប់ជាតិផ្ទាល់របស់រដ្ឋជាសមាជិកត្រូវគេអនុវត្ត កថាខ័ណ្ឌ៣៣ នៃសេចក្តីសម្រេចនេះ

១៨. យោងតាមគោលការណ៍នៃការទទួលស្គាល់ សារៈប្រយោជន៍ផ្លូវច្បាប់ដ៏សំខាន់នៃការអនុវត្តការជំនុំជម្រះតែមួយលើកនៅក្នុងប្រព័ន្ធភាគច្រើន គឺជាការហាមប្រាម (និងមិនអនុញ្ញាត) ឱ្យមានការកាត់ទោសជាបន្តបន្ទាប់ដោយផ្អែកលើអង្គហេតុតែមួយ[២២] ។

១៩. ទាក់ទងទៅនឹងអត្ថន័យនៃពាក្យ Idem បណ្ដាប្រទេសភាគច្រើនបានកំណត់និយមន័យពាក្យនេះថាជា *ព្រឹត្តការណ៍ជាក់ស្ដែងជាប្រវត្តិសាស្ត្រ* ដែលជាផ្នែកមួយនៃការជំនុំជម្រះពីពេលមុនមក[២៣] ។ បណ្ដាប្រទេសផ្សេងទៀតផ្ដោតលើបទល្មើសឧក្រិដ្ឋដែលគេងាយសំគាល់[២៤] ។ ប៉ុន្តែបើយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលជាច្បាប់នៅជាធរមានហើយមានចែងច្បាស់ទាក់ទងទៅនឹងចំនុចនេះ ដែលថាគេមិនអនុញ្ញាតឱ្យមានការកាត់ទោសជនណាម្នាក់ឡើងវិញបានចំពោះអង្គហេតុតែមួយ តែគេអាចធ្វើទៅបានក្នុងករណីលក្ខណៈសម្បត្តិផ្លូវច្បាប់ផ្សេងទៀត ។ បញ្ញត្តិនេះស្របនឹងច្បាប់នៃប្រទេសផ្សេងទៀតហើយមិនផ្ទុយនឹងបទដ្ឋានអន្តរជាតិដែរ ។

២០. ការអះអាងរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត[២៥] ដែលថាការកាត់ទោសត្រួតគ្នាអាចធ្វើទៅបានចំពោះអំពើដូចគ្នា ទោះបីបើជនជាប់ពាក់ព័ន្ធត្រូវបានកាត់ទោសរួចហើយ ហើយមិនស្របទៅនឹងច្បាប់អន្តរជាតិ ឬ ច្បាប់ករណី[២៦] ។ ការចោទប្រកាន់ត្រួតគ្នា អាចធ្វើទៅបាននៅក្នុងការជំនុំជម្រះដដែលណាដែលអំពើមួយអាចត្រូវបានបង្រួមតាមលក្ខណៈផ្លូវច្បាប់ផ្សេងគ្នា ។

២១. លក្ខន្តិកៈនៃសាលាជម្រះក្ដីព្រហ្មទណ្ឌអន្តរជាតិសំរាប់អតីតយូហ្គោស្លាវី (ICTY) នៃសាលាជម្រះក្ដីព្រហ្មទណ្ឌអន្តរជាតិសំរាប់រ៉ូវ៉ាន់ដា (ICTR) និងនៃតុលាការពិសេសសំរាប់សៀរ៉ាឡេអូន (SCSL)

---

[២២] ដូចគ្នាអញ្ចឹងដែរ តុលាការយុត្តិធម៌អឺរ៉ុប ក្នុងរឿងក្ដីប្រឆាំង Leopold Henri Van Esbroeck C-៤៣៦/០៤ ចុះថ្ងៃទី ៩ មីនា ២០០៦ កថាខ័ណ្ឌ២ នៃសេចក្ដីសង្ខេប "បទល្មើស.......ត្រូវគេបកស្រាយ......ជាការសំគាល់នៃអំពើជាសត្យានុម័ត ដែលគេយល់ថាជាការកើតមាននៅក្នុងអង្គហេតុជាច្រើន ដែលស៊ីសង្វាក់គ្នា ដោយគ្មានការចាត់ប្រភេទនៃអំពើដែលផ្ដល់ដល់ពួកគេ ឬការពារផលប្រយោជន៍ផ្លូវច្បាប់"

[២៣] José Luis de Lacuesta យុត្តាធិការព្រហ្មទណ្ឌជាតិ និងអន្តរជាតិដែលកើតឡើងស្របគ្នា និងគោលការណ៍អំពី "ការជំនុំជម្រះតែមួយលើក របាយការណ៍ទូទៅនៅក្នុង Revue ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ២០០២ volume ៧៣ ទំព័រ៧០៧ paras ១៩ ដោយប្រៀបធៀបទៅនឹងបណ្ដាប្រទេសជាច្រើន

[២៤] ចូរមើល កំណត់សំគាល់លេខ ២២ supra កថាខ័ណ្ឌ ២០

[២៥] ដីកាឃុំខ្លួនបណ្ដោះអាសន្ន ឯកសារតុលាការ C២២ កថាខ័ណ្ឌ ៨ និង ៩

[២៦] រឿងក្ដីទាំងនេះត្រូវគេដកស្រង់ក្រោមលេខយោងពីលេខ៣ ដល់ លេខ៥ ក្នុងដីកាឃុំខ្លួនបណ្ដោះអាសន្ន ដែលនិយាយយោងទៅកន្លែងដទៃទៀត

00189494



C22/I/35

(មាត្រា ១០ (២), ៩ (២) និង ៩ (២) ដាច់ដោយឡែកពីគ្នា) អនុញ្ញាតិឱ្យមានការជំនុំជម្រះសារជាថ្មីឡើងវិញនៅចំពោះមុនសាលាក្តីពិសេសអន្តរជាតិបាន តែករណីណាដែលការប្រព្រឹត្តនេះត្រូវបានគេចាត់ទុកដោយឡែកថាជា "បទឧក្រិដ្ឋធម្មតា" ឬមួយតុលាការជាតិមិនបានធ្វើកាត់ទោសដោយម៉ត់ចត់ ដោយលំអៀង ឬមិនឯករាជ្យ ឬប្រសិនបើការអន្តរាគមន៍របស់តុលាការប្រព្រឹត្តទៅ ដើម្បីបិទបាំងជនត្រូវចោទប្រឆាំងនឹងសេក្តីថ្លែងការណ៍នៃការទទួលខុសត្រូវព្រហ្មទណ្ឌអន្តរជាតិ។

អញ្ញត្រកម្មដែលបានរៀបរាប់ចេញពីគោលការណ៍នៃការជំនុំជម្រះតែមួយលើក ប្រើជាជំរើសដូចគេបានគូសបញ្ជាក់ដោយពាក្យ "ឬ" មួយណាក៏បានមិនត្រួតគ្នាទេ។

២២. ទាក់ទងនឹងមាត្រា ២០ (៣) ចំនុច (ក) និង (ខ) នៃលក្ខន្តិកៈទីក្រុងរ៉ូម នៃតុលាការព្រហ្មទណ្ឌ អន្តរជាតិ បទបញ្ញត្តិនានាចំពោះអញ្ញត្រកម្មគឺមានដូចតទៅៈ ប្រសិនបើតុលាការផ្សេងមួយទៀតលាក់បាំងជនដែលពាក់ព័ន្ធ ឬ ប្រសិនបើការជំនុំជម្រះនេះបានប្រព្រឹត្តទៅដោយដោយមិនឯករាជ្យ ឬដោយលំអៀង ផ្ទុយទៅនឹងបទដ្ឋាននីតិវិធីដែលទទួលស្គាល់ដោយច្បាប់អន្តរជាតិ ហើយត្រូវបានធ្វើឡើងតាមរបៀបមួយដែលមិនស្របតាមចេតនានាំខ្លួនជនដែលពាក់ព័ន្ធនោះមករកយុត្តិធម៌ ។

អញ្ញត្រកម្មទីមួយទាក់ទងនឹងពាក្យ "ការជំនុំជម្រះធ្វើឱ្យតែបាន" ដែលមានគោលបំណងលាក់បាំងជនដែលពាក់ព័ន្ធ។

អញ្ញត្រកម្មទីពីរសំដៅទៅរកបទដ្ឋាននីតិវិធីត្រឹមត្រូវដែលមានលក្ខណៈមិនលំអៀង និងអាចវាស់វែងបាន ហើយអាចវាយតម្លៃបានដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ។

ប៉ុន្តែការពិនិត្យឱ្យស៊ីជម្រៅនៃកាលៈទេសៈនេះ អាចឈានទៅដល់ការសំរេចតាមផ្លូវណាមួយក៏បាន។ គេអាចធ្វើការកាត់សេចក្តីប្រឆាំងនឹងជនត្រូវចោទ ប្រសិនបើគេសន្និដ្ឋានថាតាមមធ្យោយនេះជនត្រូវចោទត្រូវរួចខ្លួន ឬត្រូវទទួលទោសស្រាល។

ប៉ុន្តែការសំរេចអាចធ្វើទៅតាមបំណងរបស់ជនត្រូវចោទបានដែរ ប្រសិនបើគេសន្និដ្ឋានថាជនត្រូវចោទមិនបានទទួលការជំនុំជម្រះត្រឹមត្រូវ ដូច្នេះតុលាការព្រហ្មទណ្ឌអន្តរជាតិនឹងប្រែក្លាយទៅជាស្ថាប័នមួយដើម្បីការពារសិទ្ធិជាមូលដ្ឋានរបស់ជនត្រូវចោទ[២៧] ។

---

២៧ Dionysios Spinellis របាយការណ៍ (សកល) គោលការណ៍នៃការជំនុំជម្រះទោសតែមួយលើកក្នុងលិខិតុបករណ៍អន្តរជាតិ ការពិនិត្យសើរើជាអន្តរជាតិ នៃច្បាប់ព្រហ្មទណ្ឌ ២00២ "Volume ៧៣" ១១៤៥ (១១៦០)

ប៉ុន្តែ "ការមានចេតនានាំខ្លួនជនណាម្នាក់មករកយុត្តិធម៌" ហើយនិង "ការលាក់បាំងជនដែលពាក់ព័ន្ធ" នៅពេលដែលអង្គហេតុលំអៀងអាចជាការពិបាកក្នុងការបង្ហាញភស្តុតាង។

ទោះបីជាក្នុងលក្ខន្តិកៈនេះ ការមានចេតនានៃការជំនុំជម្រះជាប់ពាក់ព័ន្ធនឹងពាក្យថា "និង" ជាមួយនឹងបញ្ញត្តិផ្សេងទៀតដូចជាដំណើរការនីតិវិធី ភាពឥតលំអៀង ឬឯករាជ្យក៏ដោយ ក៏លក្ខណៈវិនិច្ឆ័យនៃចេតនាតិចតួចនេះត្រូវតែជារឿងបន្ទាប់បន្សំ។

២៣. អាស្រ័យហេតុនេះ ការជំនុំជម្រះឆ្នាំ ១៩៧៩ ត្រូវតែពិនិត្យឱ្យបានស៊ីជម្រៅ ដើម្បីកំណត់ថាតើការផ្តន្ទាទោសលើកមុនរបស់ជនត្រូវចោទ គឺជាការរារាំងដល់ការកាត់ទោសនៅពេលបច្ចុប្បន្នឬអត់។

**គ. ការជំនុំជម្រះឆ្នាំ ១៩៧៩**

២៤. កំណត់សំគាល់បឋម

គួរពិនិត្យពិចារណាដែលថាការកាត់សេចក្តីឆ្នាំ ១៩៧៩ គឺជាការជំនុំជម្រះបទឧក្រិដ្ឋប្រល័យពូជសាសន៍ដំបូងបន្ទាប់ពីការជំនុំជម្រះនៅ "ទីក្រុងតូក្យូ និងណឺរំបឺ" (Tokyo and Nuremberg)។ ថ្វីត្បិតតែតុលាការឆ្នាំ ១៩៧៩ ត្រូវបានបង្កើតឡើង ហើយមានសមិទ្ធិផលក្នុងការប្រមូលភស្តុតាងក៏ដោយ ប៉ុន្តែតុលាការនេះមិនមានសមត្ថកិច្ច និងលក្ខណៈសម្បត្តិគ្រប់គ្រាន់ទេ ស្ថិតក្នុងស្ថានភាពដែលប្រទេសកម្ពុជានាពេលនោះប្រព័ន្ធច្បាប់មិនត្រូវបានបង្កើតនៅឡើយ និងមិនមានចៅក្រមវិជ្ជាជីវៈត្រឹមត្រូវចូលរួមនៅក្នុងដំណើរការកាត់ក្តីនេះ ហើយស្ថានភាពនាពេលនោះកំពុងស្ថិតនៅក្នុងភាពចំរូងចំរាស់។

លោក John Quigley អ្នកសង្កេតការណ៍ និងអ្នកជំនាញអន្តរជាតិបានកត់សម្គាល់ថា "នៅពេលដែលគេរៀបចំសវនាការនោះ ទីក្រុងភ្នំពេញ គឺជាទីក្រុងខ្មោច ទទេស្អាតគ្មានមនុស្សរស់នៅដោយសារខ្មែរក្រហម។ ប្រតិកម្មដំបូងរបស់ខ្ញុំ នៅពេលដែលខ្ញុំមកដល់ទីក្រុងភ្នំពេញ គឺខ្ញុំឆ្ងល់ថាហេតុអ្វីបានជាគេខ្វល់ខ្វាយបង្កើតឱ្យមានសវនាការនេះធ្វើអី បើជីវភាពរបស់ប្រជាជនមិនទាន់ស្តារឱ្យធម្មតាវិញផង។[២៨]" សាវនការបានផ្តល់ឱកាសឱ្យសាក្សី និងជនរងគ្រោះ (រួមទាំង ដើមបណ្តឹងរដ្ឋប្បវេណី) ឱ្យផ្តល់សក្ខីភាពអំពីទុក្ខវេទនារបស់ពួកគេ។ បើទោះជាមានការខំប្រឹងប្រែងឱ្យការកាត់ទោសឆ្នាំ ១៩៧៩

---

២៨ សូមមើលកថាខណ្ឌទី ៨ ទំព័រ ១

ភ្លាមក៏ដោយ "វាគឺជាចរន្តនៃសង្គ្រាមត្រជាក់ដែលរុញច្រានឱ្យមានការជំនុំជម្រះនេះ[២៩] ហើយគ្មាននរណាអើពើនឹងការកាត់ក្តីដោយខ្មែរខ្លួនឯងនោះទេ"[៣០]។ ដូច្នេះទើបមានទាំងការជំរុញ និងការគាំទ្រជាលក្ខណៈអន្តរជាតិក្នុងការប៉ុនប៉ងនាំជនទទួលខុសត្រូវទៅកាត់ទោសឡើងវិញឱ្យបានត្រឹមត្រូវ។

(១). យោងតាមមាត្រា ១៤ (៣) ចំនុច (ខ) នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[៣១] ជនត្រូវចោទ "ត្រូវមានពេលវេលាព្រមទាំងការសំរួលគ្រប់គ្រាន់ ដើម្បីរៀបចំការការពារខ្លួន និងទាក់ទងជាមួយមេធាវីដែលខ្លួនជ្រើសរើស"។

មូលដ្ឋានច្បាប់ដែលអង្គជំនុំជម្រះឆ្នាំ ១៩៧៩ យោងនោះ គឺក្រឹតច្បាប់លេខ ០១ ចុះថ្ងៃទី ១៥ កក្កដា ឆ្នាំ១៩៧៩ ការចោទប្រកាន់ធ្វើនៅថ្ងៃ ៣០ ខែកក្កដា ឆ្នាំ១៩៧៩ ហើយសវនាការចាប់បើកនៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៩។[៣២] ជាក់ស្តែង គេមិនបានផ្តល់ពេលវេលាគ្រប់គ្រាន់ឱ្យជនត្រូវចោទការពារខ្លួនចំពោះមុខច្បាប់ទេ។ នេះគឺជាការរំលោភសិទ្ធិជនត្រូវចោទ ដែលទទួលការជំនុំជម្រះតែពីរសប្តាហ៍បន្ទាប់ពីការចោទប្រកាន់ និងតែរយៈពេលមួយខែបន្ទាប់ពីចេញក្រឹត្រច្បាប់។ ការការពារខ្លួនចំពោះមុខច្បាប់ដ៏មិត់ចត់ក្នុងរឿងក្តីដ៏ធំបែបនេះមិនអាចប្រព្រឹត្តទៅបានទេក្នុងរយៈពេល៤សប្តាហ៍នោះ។ សហមេធាវីការពារក្តីបានលើកឡើងក្នុងសារណាថា មានការរំលោភគោលការណ៍ជាមូលដ្ឋានដែលមានចែងនៅក្នុងមាត្រា ១៤ (៣) ចំនុច (ខ)។

(២). យោងតាមក្រឹតច្បាប់លេខ ២៥[៣៣] តុលាការមានសមាសភាពមកពី " ទីប្រឹក្សាតុលាការចំនួន ១០នាក់"។ សមមិត្ត កែវ ចន្ទា ប្រធានតុលាការ ដែលជាសមាជិកក្រុមប្រឹក្សាបដិវត្តន៍កម្ពុជា និង ជារដ្ឋមន្ត្រីក្រសួងឃោសនាកា វប្បធម៌ និងព័ត៌មាន។ ក្នុងចំណោមចៅក្រមបម្រុង និងចៅក្រមប្រឹក្សាមួយចំនួនមានសញ្ញាបត្រ័ច្បាប់ ហើយធ្លាប់ប្រកបវិជ្ជាជីវៈនេះមុនរបបខ្មែរ

---

២៩ បន្ថែមដោយអ្នកសរសេរអត្ថបទនេះ

៣០ "រួចខ្លួនពីបទប្រល័យពូជសាសន៍?" ដោយ Tom Fawthrop and Helen Javis 2005

៣១ មាត្រា ៣៣ថ្មីនៃច្បាប់ស្តីពី ការបង្កើតអ.វ.ត.ក ចែងយោងទៅមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

៣២ សូមមើលកំណត់សម្គាល់ Supra លេខ ៨ ទំព័រ៤៥-៤៧ ទំព័រ៤៦៣-៤៨៨ ទំព័រ៥២៣

៣៣ សូមមើលកំណត់សម្គាល់ Supra លេខ ៨ ទំព័រ៥០-៥១

ក្រហម។[៣៤] ប៉ុន្តែតុលាការបដិវត្តន៍ប្រជាជនកម្ពុជានៅពេលនោះ គឺដូចសាលាជំរះក្តីរបស់ប្រជាជនដែលមកពីផ្នែកផ្សេងៗជាច្រើននៃសង្គមស៊ីវិលជាជាងតុលាការដែលមានវិជ្ជជីវៈត្រឹមត្រូវ។ ចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរទាំងនេះ តុលាការប្រជាជនដែលមានសមាសភាពភាគច្រើនមកពីប្រជាជនធម្មតាមិនសមជាស្ថាប័នដែលអនុវត្តនីតិរដ្ឋនោះទេ។ សមាសភាពតុលាការនេះបង្ហាញរួចទៅហើយថា វាជាស្ថាប័នដែលមានការលើកទឹកចិត្តផ្នែកនយោបាយជាជាងតុលាការឯករាជ្យ អព្យាក្រឹត ឥតលំអៀង។

(៣). តុលាការឆ្នាំ ១៩៧៩ គឺជាតុលាការជំនុំជម្រះក្តីលើកទីមួយ និងជាលើកចុងក្រោយ (បិទផ្លូវតវ៉ា)[៣៥]។ សិទ្ធិប្តឹងឧទ្ធរណ៍ដូចដែលមានចែង ក្នុងមាត្រា ៦ នៃកតិកាសញ្ញាការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន[៣៦] ព្រមទាំងមានចែងក្នុងកតិការសញ្ញាផ្សេងទៀតត្រូវបានគេរំលោភបំពាន។ បើទោះបីជាសិទ្ធិប្តឹងឧទ្ធរណ៍មិនមែនជាសិទ្ធិដាច់ខាតក្នុងករណី ដែលតុលាការកំពូលបានសម្រេចក៏ដោយ ប៉ុន្តែករណីនេះតុលាការនេះគួតែមានចៅក្រមវិជ្ជាជីវៈហើយអាចបំពេញការងារប្រកបដោយប្រសិទ្ធិភាព[៣៧]។ នៅក្នុងរឿងក្តីបច្ចុប្បន្ន ជនត្រូវចោទត្រូវបានកាត់ទោស

---

[៣៤] គោលការណ៍កាត់ក្តីដោយយុត្តិធម៌ របស់វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ http://www.khmerrough.com/pdf/FairTrialPrinciples160606.pdf, page 3 បើកនៅថ្ងៃទី ២ ឧសភា ២០០៨ ម៉ោង ១៦:០០

[៣៥] សូមមើលកំណត់សម្គាល់ Supra លេខ ៨ ទំព័រ ៥២៣

[៣៦] កតិការសញ្ញាការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ឆ្នាំ ១៩៥០ រួមបញ្ចូលជាមួយមាត្រា២នៃពិធីសារលេខ៧ នៃកតិការសញ្ញាការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ឆ្នាំ១៩៨៤ និងមាត្រា ២នៃកតិការសញ្ញានេះ:" សិទ្ធិប្តឹងឧទរណ៍ករណីព្រហ្មទណ្ឌចែងថា : ១. ជនគ្រប់រូបដែលត្រូវបានតុលាការផ្តន្ទាទោសពីបទ ថាបានប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌណាមួយ ជននោះមានសិទ្ធិស្នើរសុំឱ្យតុលាការថ្នាក់លើសើរើ ការផ្តន្ទាទោស ឬការកាត់ទោសមកលើខ្លួនបាន។ . ការប្រើប្រាស់ សិទ្ធិនេះ រួមទាំងការលើកឡើងមូលហេតុនានាត្រូវតែគោរពតាមច្បាប់។ ២. គេអាចលើកលែងមិនអនុវត្តសិទ្ធិនេះចំពោះបទល្មើសស្រាលៗ ដូចដែលមានចែងក្នុងច្បាប់ រឺក្នុងករណីដែលការកាត់ទោសនោះធ្វើឡើងលើកដំបូងដោយតុលាការជាន់ខ្ពស់ រឺបុគ្គលដែលគេកាត់ទោស ធ្វើតាមការប្តឹងឧទ្ធរណ៍ប្រឆាំងការសំរេចឱ្យរួចខ្លួន។" សិទ្ធិប្តឹងឧទ្ធរណ៍ មានចែងនៅក្នុង ECHR ពិធីសារ ៧ មាត្រា២ ក្នុងកតិការសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ មាត្រា ១៤(៥)។

[៣៧] សូមមើលកំណត់សម្គាល់ Supra លេខ ៨ ទំព័រ ៨ របស់ John Quigley ដោយត្រូវគេអញ្ជើញឱ្យធ្វើជាអ្នកជំនាញការអន្តរជាតិ និងធ្លាប់មានបទពិសោធន៍ផ្នែកច្បាប់ អន្តរជាតិ និងក្នុងស្ថាប័នមេធាវីអាមេរិច ដែលផ្តោតលើបញ្ហាប្រល័យពូជន៏សាសន៍ John Quigley បានសន្និដ្ឋានថា: "មកដល់ត្រឹមខែសីហា ឆ្នាំ១៩៧៩ គ្មានអ្នកណាប្រកបវិជ្ជាជីវៈច្បាប់ នៅក្នុងប្រទេសនេះទេ ហើយក៏គ្មានតុលាការធម្មតាទៀត។ គ្មានបុគ្គលិកណាម្នាក់ដែលមានចំណេះដឹងតាមបែបវិទ្យាសាស្ត្រស្តីពី ការប្រមូលភស្តុតាង។ លើសពីនេះ ការរើសអើងប្រឆាំងនឹងជនដែលគេចោទប្រកាន់ គឺជៀសមិនរួចទេក្នុងស្ថានភាពបែបនេះ....។ ក្នុងឆ្នាំ ១៩៧៩ វាមានការពិបាកក្នុងការស្វែងរកជនកម្ពុជាដែលមិនបានគិតទុកជាមុនថា ប៉ុល ពត និង អៀង សារី គ្មានទោសនោះ។

00189498



ដោយតុលាការប្រជាជនបដិវត្តន៍កម្ពុជាដែលមិនស្របទៅតាមបទដ្ឋាននៃតុលាការដែលមានវិជ្ជាជីវៈ។ ដូច្នេះសិទ្ធិប្តឹងឧទ្ធរណ៍ មិនត្រូវបានគេផ្តល់ឱ្យជនដែលគេកាត់ទោស ហើយនេះជាការរំលោភទៅលើសិទ្ធិរបស់ពួកគេ ដូចដែលបានលើកឡើងនៅក្នុងកតិកាសញ្ញាខាងលើ។

(៤). ពាក្យដែលគេប្រើនៅក្នុងក្រឹតច្បាប់ដែលបង្កើតតុលាការនេះដូចជា "បនប៉ុល ពត អៀង សារី" បង្ហាញថាតុលាការនេះ មិនត្រឹមតែលំអៀងទេ ថែមទាំងមិនឯករាជ្យទៀត[៣៨]។ ពាក្យនេះបង្ហាញឱ្យឃើញច្បាស់ថាតុលាការបដិវត្តន៍ប្រជាជនកម្ពុជា មានភាពលំអៀង ហើយបុរេនិច្ឆ័យ។
ដូចនេះសិទ្ធិរបស់ជនត្រូវចោទ និងទណ្ឌិត ក្នុងការទទួលបានការជំនុំជម្រះដោយតុលាការដែលមិនលំអៀង និង ឯករាជ្យត្រូវគេរំលោភ។

(៥). សាក្សីមិនត្រូវបានគេសួរដេញដោលដោយម៉ត់ចត់ និងល្អិតល្អន់ឡើយនៅពេលសវនាការ។ មេធាវីការពារក្តីបាន ប្រើសិទ្ធិរបស់ខ្លួនតែបន្តិចបន្តួចប៉ុណ្ណោះ។ នេះបង្ហាញថាមេធាវីការពារក្តីមិនបានបំពេញភារកិច្ចរបស់ខ្លួនដោយយកចិត្តទុកដាក់ទេ[៣៩] ហើយគ្រាន់តែបង្ហាញចំណាប់អារម្មណ៍ថាការជំនុំជម្រះនេះស្របតាមបទដ្ឋានអន្តរជាតិ។

(៦). ចៅក្រមម្នាក់ក្នុងចំណោមចៅក្រមកាត់សេចក្តីទាំង១០រូប បានដាក់បញ្ចូលសេចក្តីថ្លែងការណ៍ដោយអះអាងថាខ្លួនជាជនរងគ្រោះ[៤០] ចំណែកចៅក្រមម្នាក់ទៀតដែលជាវេជ្ជបណ្ឌិតបានសរសេរក្នុងរបាយការណ៍អំពីផលប៉ះពាល់នៃគោលនយោបាយខ្មែរក្រហមទៅលើសុខភាពកុមារ[៤១]។ ឧទាហរណ៍ទាំងនេះបង្ហាញថាមានការលំអៀងប្រឆាំងនឹងជនជាប់ចោទ និងក្រោយមកផ្តន្ទាទោសឱ្យទទួលខុសត្រូវតែតំបន់ណាមួយប៉ុណ្ណោះ ហើយក៏បង្ហាញផងដែលថាការជំនុំជម្រះនោះ មិនឯករាជ្យ និងលំអៀង។

---

[៣៨] ទោះបីជាបែបនេះក៏ដោយគេមិនដឹងថា តើតុលាការនេះដោះស្រាយតាមរបៀបផ្លូវកាត់ដូចក្នុងការជំនុំជម្រះប្រឆាំងនឹង "Baader-Meinhof_Bnde" នៅអាល្លឺម៉ង់ក្នុងទសវត្សទី៧០។ ការជំនុំជម្រះនាពេលនោះទទួលរងការរិះគន់យ៉ាងខ្លាំងថាមានភាពលំអៀង។

[៣៩] សូមមើលកំណត់សម្គាល់ Supra លេខ ៨ ទំព័រ១៥

[៤០] សូមមើលកំណត់សម្គាល់ Supra លេខ ៨ ទំព័រ៨

[៤១] សូមមើលកំណត់សម្គាល់ Supra លេខ៣៥

(៧). ការជំនុំជម្រះឆ្នាំ ១៩៧៩ កើតឡើងដោយមានការជំរុញផ្នែកនយោបាយ ដើម្បីឱ្យអន្តរជាតិទទួលស្គាល់របបថ្មី។ លោក រស់ សាមី ដែលជាមន្ត្រីរដ្ឋាភិបាលបានរិះគន់ក្នុងពិធីបដិសណ្ឋារកិច្ចមួយនៅប្រទេសចិន និងសហរដ្ឋអាមេរិច "ចំពោះការព្យាយាមគ្រប់មធ្យោបាយដើម្បីលាក់បាំង និងផ្តល់ជំនួយដល់ក្រុមដែលនៅសេសសល់ពីបនប៉ុល ពត អៀង សារី ក្នុងបំណងដើម្បីស្តាររបបប្រល័យពូជសាសន៍យង់ឃ្នងនៅកម្ពុជា" ហើយថាការបង្កើតតុលាការ " ដាក់នៅមុខប្រជាពលរដ្ឋកម្ពុជា និង អ្នកស្នេហាសន្តិភាព និងកងកំលាំងប្រដាប់អាវុធអ្នកដែលមានគំនិតជឿនលឿនក្នុងពិភពលោក ដែលជាបញ្ហាបន្ទាន់ដែលនឹងបញ្ចប់ឥទ្ធិពលបនប៉ុល ពត អៀង សារី ហើយទន្ទឹមនឹងនេះទប់ស្កាត់បទឧក្រិដ្ឋកម្មរបស់ប្រទេសវាតទីនិយមចិនប៉េកាំង និងអំពើដូច១គ្នានោះ"[៤២]។ ជាលទ្ធផល ការជំនុំជម្រះឆ្នាំ១៩៧៩ គឺជាការជំនុំជម្រះមិនឯករាជ្យ និងលំអៀង។ ដូច្នេះការជំនុំជម្រះនេះរំលោភលើបទដ្ឋានអន្តរជាតិនៃ *ភាពមិនលំអៀង* និង *ឯករាជ្យ* ហើយជនជាប់ចោទមិនអាចសំអាងលើការកាត់សេចក្តីនេះ និងអះអាងថាខ្លួនត្រូវគេកាត់ទោសរួចហើយនោះទេ[៤៣]។

២៥. ក្នុងពេលនោះ ចៅក្រមប្រធានអង្គជំនុំជម្រះ ឆ្នាំ១៩៧៩ លោក កែវ ចន្ទា កាន់តំណែងជារដ្ឋមន្ត្រីឃោសនាការ ព័ត៌មាន និងវប្បធម៌ ហើយក៏ជាប្រធានគណៈកម្មាធិការកិច្ចការច្បាប់។ នៅថ្ងៃទី ២៨ កក្កដា ឆ្នាំ១៩៧៩ នៅមុនពេលបើកសវនាការ គាត់បានរៀបចំឱ្យមានសន្និសិទ្ទសារព័ត៌មាន[៤៤] គឺពេលនោះហើយបង្ហាញយ៉ាងច្បាស់ថា គាត់មានភាពលំអៀងបែបណា។ ការជំនុំជម្រះនេះត្រូវគេកំណត់មុនរួចជាស្រេចទៅហើយ។ សូមជូនឧទាហរណ៍ខ្លះពីអ្វីដែលគាត់បាននិយាយៈ "វាច្បាស់ណាស់ថាបនប៉ុល ពត អៀង សារី បានប្រព្រឹត្តបទឧក្រិដ្ឋប្រល័យពូជសាសន៍មិនត្រឹមតែប្រឆាំងទៅលើក្រុមជាតិពន្ធ រឺប្រឆាំងទៅលើប្រជាជនក្នុងសង្គមគ្រប់ជាន់ថ្នាក់ប៉ុណ្ណោះទេ ថែមទាំងប្រឆាំងប្រជាពលរដ្ឋកម្ពុជាទាំងមូលទៀតផង[៤៥]។ បនប៉ុល ពត អៀង សារី បានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងប្រជាជនទូទាំង

---

[៤២] សូមមើលកំណត់សម្គាល់ Supra លេខ ៨ ទំព័រ៨

[៤៣] សារណារបស់ អៀង សារី ចុះថ្ងៃទី ៧ ខែមេសា ២០០៨ កថាខណ្ឌ១១-២៥ ERN00១៧៧២៦៥-00១៧៧២៨០ ឯកសារតុលាការលេខ: C២២/I/២៦

[៤៤] សូមមើលកំណត់សម្គាល់ Supra លេខ ៨ ទំព័រ៤៧ ដល់៤៩ ឯកសារដែលជាសន្ទរកថារបស់ កែវ ចន្ទា

[៤៥] សូមមើលកំណត់សម្គាល់ Supra លេខ ៨ ទំព័រ៤៨ ការគូសបញ្ជាក់បន្ថែម

ប្រទេសរបស់ខ្លួន[៤៦]។ ហេតុដូច្នេះហើយ ហេតុការណ៍នេះបានបង្ហាញថាអង្គជំនុំម្រះ គឺលំអៀង និងមិនមានឯករាជ្យទាល់តែសោះ។ គោលការណ៍សន្មតទុកជាមុនថាគ្មានទោស ជាទូទៅ និងសំខាន់ ដែលគេទទួលស្គាល់ទូទាំងពិភពលោកត្រូវគេរំលោភបំពានទាំងស្រុង។

២៦. ដោយមានចៅក្រមជាប្រធានលំអៀង បញ្ញត្តិផ្សេងទៀតហាក់ដូចជារំលោភសិទ្ធិជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយតុលាការដែលមិនលំអៀង និងឯករាជ្យ។ នៅថ្ងៃទី៤ សីហា ឆ្នាំ១៩៧៩ ចៅក្រមប្រធានក្រុមប្រឹក្សា កែវ ចន្ទា បានសម្រេចអំពីនីតិវិធីជំនុំជម្រះ ហើយបានចេញសេចក្តីថ្លែងការណ៍មួយថា"ព្រះរាជអាជ្ញា ជនជាប់ចោទ និងមេធាវី គ្មានសិទ្ធិសួរនាំអំពីការផ្លាស់ប្តូរសមាសភាពចៅក្រមតុលាការបដិវត្តន៍ប្រជាជនទេ។"[៤៧]

ដូច្នេះ ការជំទាស់នឹងចៅក្រមប្រធានត្រូវបានគេបដិសេធរួចទៅហើយនៅក្នុងនីតិវិធីជំនុំជម្រះ។

២៧. ភាពទុកចិត្តបានទៅលើសាក្សីក៏ត្រូវបានគេចោទសួរផងដែរ។ ការលើកឡើងខ្លះរួមទាំងការប្រកាសពីភាពស្មោះត្រង់ ចំពោះរដ្ឋាភិបាល ដូចជាការសម្តែងការដឹងគុណចំពោះរដ្ឋាភិបាលថ្មី និងកងទ័ពរំដោះ។ សាក្សីជាច្រើនប្រើពាក្យដោយឡែករបស់រដ្ឋាភិបាលថ្មី។ ប្រការនេះបង្ហាញឱ្យឃើញចំណាប់អារម្មណ៍ថាសាក្សីចង់ផ្តាច់ខ្លួនឱ្យឆ្ងាយពីរបបចាស់ ហើយចង់បង្កើតទំនាក់ទំនងល្អជាមួយរដ្ឋាភិបាលថ្មី។[៤៨] ដូច្នោះគេថាក្នុងស្ថានភាពបែបនេះ និងបរិយាកាសនៃសង្គ្រាមត្រជាក់សាក្សីខ្លះ"អាចបន្ថែមបន្ថយអង្គហេតុដើម្បីការពារការអះអាងរបស់គេ"។[៤៩]

២៨. ការរំលោភបំពានធ្ងន់ធ្ងរជាច្រើនលើសិទ្ធិជនជាប់ចោទ នាំឱ្យយើងឈានដល់ការសន្និដ្ឋានថាការជំនុំជម្រះការពីមុនមិនអាចមានអនុភាពមកដល់បច្ចុប្បន្នទេ។ គោលការណ៍ជាមូលដ្ឋាននៃការទទួលបានការជំនុំជម្រះដោយតុលាការឯករាជ្យ និងឥតលំអៀងត្រូវគេរំលោភបំពាន។[៥០]

---

៤៦ សូមមើលកំណត់សម្គាល់ Supra លេខ ៨ ទំព័រ៤៩ ការគូសបញ្ជាក់បន្ថែម

៤៧ សូមមើលកំណត់សម្គាល់ Supra លេខ ៨ ទំព័រ៤៣ បញ្ញត្តិ I.៣

៤៨ សូមមើលកំណត់សម្គាល់ Supra លេខ ៨ ទំព័រ១៥

៤៩ សូមមើលកំណត់សម្គាល់ Supra លេខ ៨ ទំព័រ១៥

៥០ មេធាវីខាងដើមបណ្តឹងរដ្ឋប្បវេណីមានការភ្ញាក់ផ្អើលជាខ្លាំង ពេលដែលបានឃើញភាពផ្ទុយគ្នារបស់ជនត្រូវចោទ ដែលម្តង យោងលើការជំនុំជម្រះឆ្នាំ១៩៧៩ ដែល រំលោភលើសិទ្ធិរបស់ជនជាប់ចោទយ៉ាងខ្លាំង និងម្យ៉ាងទៀតតវ៉ាពីភាពលំអៀងដែលលើកឡើងដោយ David Boyle និង Stephen Heder

ដូចបានគូសបញ្ជាក់ខាងលើ[៥១] សាលាក្តីពិសេសអន្តរជាតិ និងតុលាការព្រហ្មទណ្ឌអន្តរជាតិបានចែងនៅក្នុងលក្ខន្តិកៈរបស់ខ្លួននូវអញ្ញត្រកម្មពីគោលការណ៍ជំនុំជម្រះតែមួយលើក នៅក្នុងករណីដែលថាការកាត់ទោសពីមុនលំអៀង ឬមិនឯករាជ្យ។ បទបញ្ញត្តិនេះមិនជាប់ពាក់ព័ន្ធជាមួយអង្គហេតុតាមគំនិតរបស់នរណាម្នាក់ដែលមាន "ចេតនាលាក់បាំងជនណាមួយនោះទេ"។

ជនត្រូវចោទមិនអាចយោងឱ្យមានប្រសិទ្ធិភាពទៅរកការកាត់ទោសឆ្នាំ ១៩៧៩ ពីមុនបានទេ ហើយក៏មិនអាចពឹងផ្អែកលើគោលការណ៍ជំនុំជម្រះតែមួយលើកដែរ។

តាមទស្សនៈនេះ បញ្ហាថាតើការកាត់ទោសឆ្នាំ ១៩៧៩ មានអានុភាពលើអង្គហេតុដូចដែលចោទប្រកាន់នៅចំពោះមុខ អ.វ.ត.ត ដែរឬទេ ហើយថាតើនិយមន័យនៃបទប្រល័យពូជសាសន៍មិនចាំបាច់ត្រូវយកមកពិភាក្សាដែរឬទេ។

## V- ការលើកលែងទោស និងការលើកលែងជាទោសទូទៅប្រទានដោយព្រះមហាក្សត្រ

### ក. ច្បាប់ពាក់ព័ន្ធ និងនិយមន័យ

២៩. រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា[៥២] បានចែងក្នុងមាត្រា ២៧ ថា "ព្រះមហាក្សត្រទ្រង់មានព្រះរាជសិទ្ធិបន្ធូបន្ថយទោស ឬលើកលែងទោស"។

មាត្រា ៣៨ វាក្យខ័ណ្ឌ(៧) ចែងថា "ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោសដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ"។

៣០. ច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់[៥៣] បានចែងក្នុងមាត្រាដទៃទៀតដូចខាងក្រោម:

**មាត្រា ៣ :** សមាជិកអង្គការនយោបាយ និងកម្លាំងយោធារបស់ក្រុម "កម្ពុជាប្រជាធិបតេយ្យ" ឬជនណាដែលបានប្រព្រឹត្តបទឧក្រិដ្ឋធ្វើមនុស្សឃាតដោយចេតនា ចាប់បង្ខំនារីសេពសន្ថវៈ ប្លន់ទ្រព្យសម្បត្តិ

---

[៥១] ចូរមើលកថាខ័ណ្ឌ ១៥ និង១៦ នៃសារណានេះ

[៥២] រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ វិសោធនកម្ម ឆ្នាំ ១៩៩៩ ក្នុងកំរងច្បាប់ដែលនៅជាធរមាន នៅក្នុងព្រះរាជាណាចក្រកម្ពុជា ខែមករា ឆ្នាំ ២០០២

[៥៣] ច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់ ១៩៩៤ ក្នុងកំរងច្បាប់ដែលនៅជាធរមាន នៅក្នុងព្រះរាជាណាចក្រកម្ពុជា ខែមករា ឆ្នាំ ២០០២

00189502



ប្រជារាស្ត្រ បំផ្លិចបំផ្លាញទ្រព្យសម្បត្តិសាធារណៈ និងឯកជន។ល។ ត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន។

**មាត្រា ៤ :** សមាជិកនៃអង្គការនយោបាយ និងកម្លាំងយោធារបស់ក្រុម "កម្ពុជាប្រជាធិបតេយ្យ" ឬជនណាដែលបានប្រព្រឹត្តអំពើ :

- ធ្វើសកម្មភាពអបគមន៍
- បំផ្លាញរាជរដ្ឋាភិបាល
- បំផ្លាញអង្គការនៃអំណាចសាធារណៈ
- ញុះញង់ ឬបង្ខំពលរដ្ឋឱ្យកាន់អាវុធប្រឆាំងនឹងអាជ្ញាធរសាធារណៈ ត្រូវចាត់ទុកជាជនឧក្រិដ្ឋប្រឆាំងនឹងសន្តិសុខក្នុងប្រទេស ហើយត្រូវផ្តន្ទាទោសដាក់គុកពី២0ឆ្នាំ ទៅ ៣0ឆ្នាំ ឬអស់មួយជីវិត។

**មាត្រា ៥ :** ច្បាប់នេះអនុគ្រោះទុកពេល ៦ ខែ ក្រោយពីចូលជាធរមាន ឱ្យជនជាសមាជិកអង្គការនយោបាយ ឬជាកំលាំងយោធានៃក្រុម "កម្ពុជាប្រជាធិបតេយ្យ" វិលត្រលប់មករួមរស់ក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាលក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនយកទោសពៃរ៍ចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត"។

**មាត្រា ៦ :** ចំពោះមេដឹកនាំនៃក្រុម "កម្ពុជាប្រជាធិបតេយ្យ" មិនអាចមានការអនុគ្រោះដូចមានចែងក្នុងច្បាប់នេះឡើយ។

**មាត្រា ៧ :** ព្រះមហាក្សត្រទ្រង់អាចបន្ធូរបន្ថយទោស ឬលើកលែងទោសតាមព្រះរាជសិទ្ធិដែលមានចែងក្នុងមាត្រា ២៧ នៃរដ្ឋធម្មនុញ្ញ។

៣១. តាមធម្មតា គេផ្តល់*ការលើកលែងទោសជាទូទៅ* ដល់ជនដែលត្រូវគេចោទប្រកាន់ ត្រូវធ្វើឡើងមុនពេលការកាត់ទោសចំពោះបទឧក្រិដ្ឋដែលពួកគេបានប្រព្រឹត្ត ផ្ទុយទៅវិញ*ការលើកលែងទោស* ត្រូវធ្វើឡើងចំពោះអ្នកដែលត្រូវបានគេផ្តន្ទាទោសរួចហើយ។

នៅក្នុងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន បានថ្វាយព្រះមហាក្សត្រនូវព្រះរាជសិទ្ធិក្នុង*ការលើកលែងទោស* ដូចមានចែងក្នុងមាត្រា ២៧ រីឯ *ការលើកលែងទោសជាទូទៅ* មាត្រា ៩0 នៃរដ្ឋធម្មនុញ្ញដែលបានផ្តល់សមត្ថកិច្ចទៅឱ្យរដ្ឋសភា។

## ខ. ប្រសិទ្ធិភាពនៃ "ការលើកលែងទោសជាទូទៅ" ចំពោះការកាត់ទោសតាមច្បាប់ស្តីពី ការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់

៣២. បន្ទាប់ពីអត្ថន័យនៃការលើកលែងទោស ហើយទាក់ទងទៅនឹងបទបញ្ញត្តិនៅក្នុងរដ្ឋធម្មនុញ្ញដែលថា មានតែតុលាការទេដែលអាចប្រកាសថាជនណាម្នាក់មានទោស"[៥៤] ។ ព្រះរាជសិទ្ធិរបស់ព្រះមហាក្សត្រត្រូវបានកំណត់ត្រឹមការផ្តល់ការលើកលែងទោសចំពោះជនដែលគេផ្តន្ទាទោសរួចហើយ ។ យោងតាមមាត្រា ២៧ នៃរដ្ឋធម្មនុញ្ញ ព្រះមហាក្សត្រមិនមានព្រះរាជសិទ្ធិប្រកាស"ការលើកលែងទោសជាទូទៅ" ចំពោះការកាត់ទោសជាពិសេសនាពេលខាងមុខ ដោយគ្មានការផ្តន្ទាទោសពីពេលមុននោះទេ។ ព្រះមហាក្សត្រមិនមានព្រះរាជសិទ្ធិលើកលែងទោសទេ ប្រសិនបើទោសកំហុសរបស់ជនណាម្នាក់មិនបានកំណត់ដោយតុលាការ ដែលជាស្ថាប័នតែមួយគត់ប្រកាសអំពីទោសកំហុសនេះ ។ ដូច្នេះព្រះមហាក្សត្រទ្រង់អនុវត្តព្រះរាជសិទ្ធិរបស់ព្រះអង្គដែលមានចែងក្នុងរដ្ឋធម្មនុញ្ញឱ្យជនត្រូវចោទក្នុងការប្រទានការលើកលែងទោសទូទៅចំពោះការកាត់ទោសតាមច្បាប់ស្តីពី ការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យក្រៅច្បាប់ ។

៣៣. ការលើកលែងទោសទូទៅដែលមិនស្របច្បាប់ គឺមិនចងកាតព្វកិច្ចដល់ អ.វ.ត.ក ទេ ហើយក៏គ្មានការរារាំងដល់ការកាត់ក្តីដែរ ។

៣៤. នៅពេលសន្មត់ថាការប្រទានការលើកលែងទោសទូទៅរបស់ព្រះមហាក្សត្រ មានចែងអំពីព្រះរាជសិទ្ធិរបស់ព្រះអង្គនៅក្នុងរដ្ឋធម្មនុញ្ញ សហព្រះរាជអាជ្ញាដើមបណ្តឹងរដ្ឋប្បវេណីសូមស្នើថាការទទួលបាននូវការលើកលែងទោសទូទៅរបស់ព្រះមហាក្សត្រមានន័យថាជានិទណ្ឌភាព ។

ចាប់តាំងពីការបង្កើតឱ្យមានសាលាក្តីពិសេសអន្តរជាតិ និងតុលាការព្រហ្មទណ្ឌអន្តរជាតិ ព្រមទាំងដំណើរការជោគជ័យដ៏ទូលំទូលាយ ជាពិសេសនៅក្នុងអាមេរិកឡាទីនប្រឆាំងនិងវប្បធម៌និទណ្ឌភាពរបស់ប្រមុខរដ្ឋ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត ជាទូទៅការរារាំងចំពោះការកាត់ទោសលើបទឧក្រិដ្ឋធ្ងន់ធ្ងរនេះ សហគមន៍អន្តរជាតិលែងគេទទួលស្គាល់ទៀតហើយ ។

៣៥. ទោះបីជាមានការបញ្ចប់សង្គ្រាមដែលកំពុងបន្ត និងការធ្វើកិច្ចព្រមព្រៀងសន្តិភាពដែលបូកបញ្ចូលការលើកលែងទោសជាទូទៅចំពោះអតីតកងកំលាំងប្រដាប់អាវុធ និងអ្នកតស៊ូក៏ដោយ ក៏មិនអាចដាក់បញ្ចូលនូវការលើកលែងទោសទូទៅសរុបទាំងអស់ចំពោះអ្នកទទួលខុសត្រូវខ្ពស់បំផុតដែរ[៥៥] ។

---

[៥៤] ចូរមើលមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ

បន្ថែមពីនេះទៀត ការលើកលែងទោសទូទៅបែបនេះបានរំលោភកាតព្វកិច្ចអន្តរជាតិ ដើម្បីកាត់ទោសឧក្រិដ្ឋកម្មធ្ងន់ធ្ងរតាមច្បាប់អន្តរជាតិ ។

៣៦. នៅថ្ងៃទី ១៨ មីនា ២០០៤[៥៦] តុលាការពិសេសសំរាប់សៀរ៉ាលេអូន បានច្រានចោលការលើកលែងទោសជាទូទៅក្នុងការសម្រេចចិត្តដ៏សំខាន់មួយ ។ តុលាការពិសេសនេះពិនិត្យពិចារណាថា ការគេផ្តល់ការលើកលែងទោសជាទូទៅនៅឆ្នាំ១៩៩៩ ក្នុងកិច្ចព្រមព្រៀងសន្តិភាព Lomé គឺ "មិនមានប្រសិទ្ធិភាព"ទេ ក្នុងការរារាំងតុលាការអន្តរជាតិ ដូចជា តុលាការពិសេសសំរាប់សៀរ៉ាលេអូន ឬតុលាការអន្តរជាតិ កុំឱ្យកាត់ទោសបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមបានទេ ។

ចៅក្រមទាំងនោះទទួលយកទ្រឹស្តីរបស់យុត្តាធិការជាសកល ។ ចៅក្រមទាំងនោះយល់ថា ការលើកលែងទោសទូទៅនេះស្ថិតនៅក្រោមអំណាចរបស់រដ្ឋ ដែលអនុវត្តនូវអំណាចអធិបតេយ្យភាពរបស់ខ្លួនគេតែប៉ុណ្ណោះ ។[៥៧]

ប៉ុន្តែ នៅកន្លែងណាដែលមានយុត្តាធិការជាសកលហើយ រដ្ឋនេះមិនអាចធ្វើឱ្យខូចយុត្តាធិការដល់រដ្ឋផ្សេងទៀតក្នុងការកាត់ទោសចារីតាមរយៈការផ្តល់ការលើកលែងទោសជាទូទៅ ។[៥៨]

សភាជាន់ខ្ពស់បានសន្និដ្ឋានថា ឧក្រិដ្ឋកម្មនៅក្នុងមាត្រា ២ ដល់ ៤ នៃលក្ខន្តិកៈនេះ គឺជាឧក្រិដ្ឋកម្មអន្តរជាតិដែលត្រូវគេផ្តន្ទាទោសតាមគោលការណ៍ជាសកល ។[៥៩]

ដូច្នេះការលើកលែងទោសទូទៅដែលផ្តល់ដោយសៀរ៉ាលីអូន មិនអាចគ្របដណ្តប់ដូចដែលមានចែងតាមច្បាប់អន្តរជាតិទេ នៅពេលដែលការលើកលែងទោសទូទៅថិតនៅក្រោមយុត្តាធិការជាសកល និង ដោយមូលហេតុថា "កាតព្វកិច្ចដើម្បីការពារសេចក្តីថ្លៃថ្នូររបស់មនុស្ស គឺជាវិធានដាច់ខាតហើយ

---

[៥៥] គាំទ្រដោយ Daniel Kemper Donovan "កិច្ចខិតខំប្រឹងប្រែងរួមគ្នារវាងកម្ពុជា-អ.ស.ប ដើម្បីបង្កើតនូវសាលាក្តីកាត់ទោសខ្មែរក្រហម" (២០០៣) ៤៤ សារព័តមានច្បាប់អន្តរជាតិ Harvard ៥៥១ ៥៧៥ ។ គេបោះឆ្នោតឱ្យមានការផ្តល់ការលើកលែងទោសទូទៅចំពោះរាល់សមាជិកខ្មែរក្រហមថ្នាក់ទាបទាំងអស់ ក្នុងលក្ខខ័ណ្ឌដែលថាពួកគេប្រាប់រឿងរ៉ាវ អំពីការចូលរួមនៅអំពើយង់ឃ្នងរបស់ពួកគេនៅពេលមេដឹកនាំជាន់ខ្ពស់គួរត្រូវបានគេកាត់ទោស ។

[៥៦] រឿងក្តីប្រឆាំងនឹង Morris Kallon and Brima Bazzy សេចក្តីសម្រេចស្តីពីបញ្ហាប្រឈមមុខទៅនឹងយុត្តាធិការៈ ការលើកលែងទោសទូទៅតាមកិច្ចព្រមព្រៀង Lomé ចុះថ្ងៃទី ១៣ មីនា ២០០៤ រឿងក្តីលេខ. SCSL ២០០៤-១៥-AR ៧២ (E) ។

[៥៧] ដូចគ្នានៅក្នុវកថាខ័ណ្ឌ ៦៧

[៥៨] ដូចខាងលើ

[៥៩] ដូចគ្នានៅក្នុងកថាខ័ណ្ឌ ៦៨ និង៧០

មានលក្ខណៈជាកាតព្វកិច្ច erga omnes"។[៦០] ដូច្នេះការផ្តល់ការលើកលែងទោសទូទៅចំពោះឧក្រិដ្ឋកម្មអន្តរជាតិទាំងនេះមិនគ្រាន់តែបំពានច្បាប់អន្តរជាតិប៉ុណ្ណោះទេ " ថែមទាំងជាការរំលោភដល់កាតព្វកិច្ចរបស់រដ្ឋចំពោះសហគមន៍អន្តរជាតិទាំងមូល"ទៀតផង។[៦១]

៣៧. ការសំរេចរបស់សភាជាន់ខ្ពស់ត្រូវគេរិះគន់ចំពោះការបង្កើតឱ្យមានច្បាប់មនុស្សធម៌អន្តរជាតិ ប៉ុន្តែការសំរេចចិត្តនេះយ៉ាងហោចណាច់ក៏ត្រូវគេទទួលស្គាល់ថាជាការសំរេចមួយដ៏សំខាន់បំផុត "ចំពោះការលុបចោលនៃការលើកលែងទោសទូទៅដល់អំពើយង់ឃ្នង"។[៦២]

៣៨. ដើម្បីគាំទ្រលទ្ធផលស្រាវជ្រាវរកឃើញទាំងនេះ គេគួរកត់សំគាល់ផងដែរថាប្រទេសកម្ពុជាបានផ្តល់សច្ចាប័នមុនការផ្តល់ការលើកលែងទោសទូទៅរបស់ព្រះមហាក្សត្យចំពោះជនត្រូវចោទ អនុសញ្ញាបនប្រល័យពូជសាសន៍[៦៣] អនុសញ្ញាហ្សឺណែវចំនួន៤[៦៤] ជាមួយនិងកាតព្វកិច្ចរបស់អនុសញ្ញាទាំងនេះដើម្បីកាត់ទោសការរំលោភបំពានធ្ងន់ធ្ងរ[៦៥] និងអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម និងអំពើឃោរឃៅ[៦៦] ដែលចងកាតព្វកិច្ចប្រទេសកម្ពុជាដែលជារដ្ឋហត្ថលេខីច្រើនជាងរដ្ឋដែលមិនមែនហត្ថលេខីច្រើនណាស់ដើម្បីឱ្យគោរពតាមសន្ធិសញ្ញាទាំងនេះ។

៣៩. ជាការពិតណាស់ ជាទូទៅការលើកលែងទោសទូទៅ និងការលើកលែងទោសត្រូវគេទទួលស្គាល់ថាជាវិធានការដ៏ចំបាច់ដើម្បីបញ្ចប់នូវជំលោះប្រដាប់អាវុធ ប៉ុន្តែត្រូវគេកំណត់ចំពោះលក្ខខណ្ឌតំរូវជាមុន

---

៦០ ដូចគ្នានៅក្នុងកថាខ័ណ្ឌ ៧១

៦១ ដូចគ្នានៅក្នុងកថាខ័ណ្ឌ ៧៣

62 Simon M. Meisenberg នីត្យានុកូលភាពនៃការលើកលែងទោសទូទៅនៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិ សេចក្តីសំរេចលើកលែងទោសទូទៅនៅ Lomé របស់តុលាការពិសេសសំរាប់សៀរ៉ាលីអូន របាយការណ៍អន្តរជាតិរបស់កាកបាទក្រហម ២00៤ លេខ ៨៥៦ ទំព័រ ៨៥១ និង Phenyo Kreiseng Rakate តើច្បាប់លើកលែងទោសទូទៅនៅសៀរ៉ាលេអូនស្របនឹងច្បាប់អន្តរជាតិឬទេ? ទស្សនាវដ្តី Mennschen Rechts 2000 Vol.3

៦៣ អនុសញ្ញាស្តីពីការទប់ស្កាត់ និងការផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ពីឆ្នាំ ១៩៤៨. ៧៨ UNTS ២៧៧ (ចូលជាធរមានថ្ងៃទី ១២ មករា ១៩៥១)

៦៤ អនុសញ្ញាហ្សឺណែវ បានផ្តល់សច្ចាប័នថ្ងៃទី ៨ ធ្នូ ឆ្នាំ១៩៥៨

៦៥ មាត្រា ១៤៦ ១៤៧ នៃអនុសញ្ញាបំពានធ្ងន់ធ្ងរលើកទី ៤

៦៦ អនុសញ្ញាប្រឆាំងអំពើទារុណកម្ម និងអំពើឃោរឃៅ អមនុស្សធម៌ផ្សេងទៀត ឬការផ្តន្ទាទោស និងការធ្វើទុកបុកម្នេញ បានផ្តល់សច្ចាប័ន ថ្ងៃទី ១៥ ខែតុលា ឆ្នាំ ១៩៩២

ពិសេសដូចជាកំរិតនៃការទទួលខុសត្រូវ កំរិត និងភាពធ្ងន់ធ្ងរនៃការប្រព្រឹត្តឧក្រិដ្ឋកម្ម[៦៧] និងកាតព្វកិច្ចរបស់រដ្ឋដើម្បីកាត់ទោសឧក្រិដ្ឋកម្ម......ដោយច្បាប់ទំលៀមទំលាប់ និងសន្ធិសញ្ញាអន្តរជាតិ ។

៤០. គណៈកម្មាធិការ[៦៨] សិទ្ធិមនុស្សអង្គការសហប្រជាជាតិ ព្រមទាំងគណៈកម្មការអន្តរអាមេរិក ស្តីពីសិទ្ធិមនុស្ស[៦៩] និងតុលាការសិទ្ធិមនុស្សអន្តរអាមេរិក បាននិយាយឡើងវិញថា[៧០] ការលើកលែងទោសទូទៅត្រូវស្របទៅនឹងកាតព្វកិច្ចរបស់រដ្ឋដើម្បីស៊ើបអង្កេតអំពើទាំងនេះ ។[៧១]

៤១. ឧទាហរណ៍ទាំងនេះបង្ហាញថា ទោះបីជាការលើកលែងទោសទូទៅរបស់ព្រះមហាក្សត្រ គួរតែបកស្រាយ នៅក្នុងជំពូកព្រះរាជសិទ្ធិរបស់ព្រះមហាក្សត្រដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញក៏ដោយ ក៏ការលើកទោសទូទៅនេះមិនស្របនឹងបទដ្ឋានអន្តរជាតិ ដូច្នេះវាមិនអាចក្លាយជាលិខិតតុករណ៍មួយនៅក្នុង អ.វ.ត.ក បានទេ ។

---

[៦៧] Naomi Roht-Arriaza កិច្ចព្រមព្រៀងសន្តិភាព និងយុត្តិធម៌អន្តរកាល ក្រុមប្រឹក្សាអន្តរជាតិស្តីពី គោលនយោបាយសិទ្ធិមនុស្ស ឆ្នាំ២០០៥ បានផ្តល់នូវទស្សនៈយល់ដឹងអំពីដំណោះស្រាយជំលោះមុនផ្សេងៗ និងការព្រមព្រៀងពួកគេទៅនឹងបទដ្ឋានអន្តរជាតិ

[៦៨] របាយការណ៍របស់គណៈកម្មាធិការសិទ្ធិមនុស្ស មហាសន្និបាទបន្ថែមលើកទី ៥៩ របស់អ.ស.ប លេខ ៤០ (A/៤៩/៤០) ទំព័រ១០

[៦៩] គណៈកម្មាអន្តរអាមេរិកស្តីពីសិទ្ធិមនុស្ស របាយការណ៍លេខ ២៨/៩២ ចុះថ្ងៃទី ២ តុលា ១៩៩២ សំណុំរឿងលេខ ១០.១៤៧ ១០.១៨១ ១០.២៤០ ១០២៦២ ១០.៣០៩ ១០.៣១១ បានអះអាងដូចតទៅថា: ក្រិត្រលើកលែងទោសរបស់ប្រទេសអាហ្សង់ទីនលេខ ១០០២ ដែលបង្គាប់ឱ្យនីតិវិធីណាដែលប្រឆាំងទៅនឹងជនដែលត្រូវចោទប្រកាន់ពីបទរំលោភសិទ្ធិមនុស្ស ដែលមិនទទួលផលប្រយោជន៍ពីច្បាប់មុនៗ កុំឱ្យបន្តទៀត ហើយនីតិនេះមិនស្របទៅនឹងអនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស និងរំលោភសិទ្ធិរបស់អ្នកប្តឹង (សន្និដ្ឋាន)

[៧០] តុលាការអន្តរអាមេរិកស្តីពីសិទ្ធិមនុស្សរឿងក្តីរបស់ Barrios Altos v. សាលក្រមរបស់ Peru ចុះថ្ងៃទី ១៤ មីនា ឆ្នាំ ២០០១ កថាខ័ណ្ឌពី ៤១ ដល់ ៤៤ "តុលាការនេះយល់ថាបទបញ្ញត្តិលើកលែងទោសទូទៅទាំងអស់ស្តីពី សេចក្តីបង្គ្រាប់ និងការបង្កើតឱ្យមានវិធានការដែលរៀបចំឡើងដើម្បីលុបបំបាត់ការទទួលខុសត្រូវនោះមិនអាចទទួលយកបានទេ ពីព្រោះវិធានការណ៍ទាំងនោះមានចេតនារារាំងការស៊ើបអង្កេតនិងការដាក់ទណ្ឌកម្មទៅលើជនដែលទទួលខុសត្រូវពីបទរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរដូចជាការធ្វើទារុណកម្ម ការប្រហារជីវិតក្រៅប្រព័ន្ធតុលាការ ការដាក់ទោសឱ្យតែបានៗ ឬព្រៃផ្សៃ ហើយនិងការធ្វើឱ្យបាត់ខ្លួន អំពើទាំងអស់ត្រូវហាមឃាត់ ពីព្រោះថាអំពើនេះរំលោភសិទ្ធិដែលមិនត្រូវបានគេមើលងាយដែលទទួលស្គាល់ដោយច្បាប់សិទ្ធិមនុស្សអន្តរជាតិ ។

[៧១] Kai Ambos Grenzuberschreitungen ១៩៩៥ ទំព័រ៣៣៥ ៣៣៦ បានពិចារណារួចជាស្រាច់ហើយឆ្នាំ ១៩៩៥ (បីឆ្នាំមុនលក្ខន្តិកៈក្រុមរ៉ូមចូលជាធរមាន) ថានៅក្នុងការប្រៀបធៀបដែលអាចយល់ដឹងបានរបស់គាត់នៃច្បាប់លើកលែងទោសទូទៅ ការលើកលែងទោស ហើយនឹងការគ្រាប្រណីទោសនៅក្នុងប្រទេសអាមេរិកឡាទីនទាំង ៥ បានលើកឡើងថា វិធានការណ៍ទាំងនេះវាផ្ទុយទៅនឹងកាតព្វកិច្ចរបស់រដ្ឋក្នុងការយកទៅកាត់ទោសទៅតាមច្បាប់អន្តរជាតិប្រសិនបើគេគិតតែការបំពាន ដ៏ធ្ងន់ធ្ងរបែបនេះ ។

00189507



00221135

### គ. ប្រសិទ្ធិនៃការលើកលែងទោសចំពោះការកាត់ក្តីឆ្នាំ១៩៧៩

៤២. ការលើកលែងទោសទូទៅរបស់ព្រះមហាក្សត្រ គ្មានអត្ថន័យផ្សេងទៀតទេ ប្រសិនបើការសម្រេចក្តីឆ្នាំ ១៩៧៩ មិនបានអនុលោមទៅតាមបទដ្ឋានស្តីពីភាពឥតលំអៀង និង ឯករាជ្យ របស់តុលាការបដិវត្តន៍ប្រជាជនកម្ពុជា ដូច្នេះវាមិនអាចរារាំងការយកទៅកាត់ទោសឱ្យត្រឹមត្រូវពិតប្រាកដបានទេ។ ការលើកលែងទោសរបស់ព្រះមហាក្សត្រ ដែលយោងលើការជំនុំជម្រះកាលពីលើកមុនគ្មានឥទ្ធិពលដល់ការកាត់ទោស និងដំណើការនីតិវិធីនាពេលខាងមុខរបស់ អ.វ.ត.ក ទេ។

## VI. ច្បាប់ពាក់ពន្ធ័ វិធាន៦៣ (៣) ចំនុច (ខ) នៃវិធានផ្ទៃក្នុង

៤៣. បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងដីកាឃុំខ្លួនបណ្តោះអាសន្ន[៧២] (ហៅថាបណ្តឹងឧទ្ធរណ៍) ត្រូវគេកម្រិត[៧៣] មកនៅលើការពិភាក្សាភ្ជាអំពីលក្ខខណ្ឌតំរូវជាមុនដែលមានចែងក្នុងវិធាន ៦៣ (៣) ចំនុច(ខ) នៃវិធានផ្ទៃក្នុង។ ដូចនេះការឆ្លើយតបរបស់សហាមេធាវីខាងភាគីដើមបណ្តឹងរដ្ឋប្បវេណីផ្តោតលើបញ្ហានេះប្រសិនបើការឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានចាំបាច់។ យោងតាមវិធាន៦៣ (៣) ចំនុច (ខ) នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេតអាចចេញដីកាឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទដោយគោរពតាមលក្ខខណ្ឌដូចខាងក្រោម:

ខ. សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ការឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានការដ៏ចាំបាច់ដើម្បី :

1. ១. រារាំងកុំឱ្យជនត្រូវចោទ គាបសង្កត់សាក្សី ឬជនរងគ្រោះ ឬរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិតចំពោះបទឧក្រិដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ។
2. ២. ថែរក្សាភស្តុតាង ឬការពារមិនឱ្យមានការបំផ្លាញភស្តុតាង។
3. ៣. ធានាអំពីវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី។
4. ៤. ការពារសន្តិសុខឱ្យជនត្រូវចោទ ឬ
5. ៥. រក្សាសណ្តាប់ធ្នាប់សាធារណៈ។

---

[៧២] សូមមើលកំណត់ត្រា Supra លេខ២

[៧៣] សូមមើលកថាខណ្ឌ លេខ៥ នៃបណ្តឹងឧទ្ធរណ៍

00189508



## VII. អង្គហេតុពាក់ពន្ធ័

៤៤. (ក). មេធាវីការពារជនត្រូវចោទបានអះអាងថាការដោះលែងជនត្រូវចោទ នឹងមិនបណ្តាលឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈទេ[៧៤] ហើយថាការិយាល័យសហចៅក្រមស៊ើបអង្កេតមិនបានបង្ហាញមូលដ្ឋានអង្គហេតុ ឬភស្តុតាង ដែលនេះជាការរំលោភលើឆន្ទានុសិទ្ធិរបស់ខ្លួន។ មេធាវីការពារជនត្រូវចោទបានដកស្រង់ពីស្ថាប័នអន្តរជាតិផ្សេងៗ[៧៥] ជាច្រើនដើម្បីបង្ហាញថាប្រទេសកម្ពុជាបច្ចុប្បន្ននេះមានស្ថេរភាពល្អណាស់។

(ខ). ដូចគ្នានេះដែរ មេធាវីការពារជនត្រូវចោទថ្លែងថា ជនត្រូវចោទ មិនមានគ្រោះថ្នាក់ទេ ហើយថាគាត់បានរស់នៅក្នុងក្រុងភ្នំពេញជាចំហដោយគ្មានការគំរាមកំហែង ឬការវាយប្រហារណាមួយឡើយរហូតដល់មានការឃុំខ្លួនគាត់[៧៦]។ ការិយាល័យសហចៅក្រមស៊ើបអង្កេតមិនបានបង្ហាញអង្គហេតុ ឬភស្តុតាងដែលនេះជាការរំលោភលើឆន្ទានុសិទ្ធិរបស់ខ្លួន។[៧៧]

(គ). លើសពីនេះទៅទៀត មេធាវីការពារជនត្រូវចោទបានលើកឡើងថា ជនត្រូវចោទមិនដែលបានគំរាមកំហែងដល់សាក្សី ទោះបីគាត់ដឹងថាមានការបង្កើត អ.វ.ត.ក ហើយដឹងថាការិយាល័យសហចៅក្រមស៊ើបអង្កេតខកខានមិនបានបង្ហាញអង្គហេតុ ហើយការសម្រេចរបស់ខ្លួនផ្អែកលើព័ត៌មានដែលមិនច្បាស់លាស់ក៏ដោយ។[៧៨]

(ឃ). ទាក់ទងនឹងការព្រួយបារម្ភពីការរត់គេចខ្លួន មេធាវីការពារជនត្រូវចោទបានគូសបញ្ជាក់ថាការិយាល័យសហចៅក្រមស៊ើបអង្កេតសំអាងតែទៅលើមូលដ្ឋានអរូបិយ និងការអះអាងដូចជាលិខិតឆ្លងដែន និងមធ្យោបាយដ៏ចាំបាច់ដ៏ទៃទៀតក្នុងការរត់គេចខ្លួន ហើយបន្ថែមទៀតថាការិយាល័យនេះមិនបានផ្តល់អង្គហេតុ និងភស្តុតាង[៧៩] ដែលនេះជាការរំលោភលើឆន្ទានុសិទ្ធិរបស់ខ្លួន។

---

[៧៤] សូមមើលកថាខណ្ឌ លេខ១០-១៥ នៃបណ្តឹងឧទ្ធរណ៍

[៧៥] សូមមើលកថាខណ្ឌ លេខ១៦-១៩ នៃបណ្តឹងឧទ្ធរណ៍

[៧៦] សូមមើលកថាខណ្ឌ លេខ២៤ នៃបណ្តឹងឧទ្ធរណ៍

[៧៧] សូមមើលកថាខណ្ឌ លេខ២៥, ២៦ នៃបណ្តឹងឧទ្ធរណ៍

[៧៨] សូមមើលកថាខណ្ឌ លេខ៣១ នៃបណ្តឹងឧទ្ធរណ៍

[៧៩] សូមមើលកថាខណ្ឌ លេខ៣៣-៣៦ នៃបណ្តឹងឧទ្ធរណ៍

ង). បន្ថែមពីលើនេះទៀត មេធាវីការពារជនត្រូវចោទអះអាងថា លក្ខខណ្ឌនៃការឃុំខ្លួនធ្វើឱ្យសុខភាពជនត្រូវចោទ ដែលមិនរឹងប៉ឹងស្រាប់ផងនោះ កាន់តែទ្រុឌទ្រោម ហើយថាគេគួរតែឃុំខ្លួនគាត់នៅក្នុងផ្ទះវិញ។

## VIII. វិសាលភាពនៃបណ្តឹងឧទ្ធរណ៍ និងតួនាទីរបស់អង្គបុរេជំនុំជម្រះ

៤៥. សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហាញយ៉ាងច្បាស់រួចហើយក្នុងសារណាតប[៨០] ទៅនឹងបណ្តឹងឧទ្ធរណ៍របស់អៀង ធីរិទ្ធ ថាបណ្តឹងឧទ្ធរណ៍នេះត្រូវតែគេកំណត់ព្រំដែនជាងនេះទៅទៀត។ សារណាទាំងនេះមិនស្របទៅនឹងឯកសារយោងភ្ជាប់មកជាមួយ។ ដូច្នេះ អង្គបុរេជំនុំជម្រះអាចបដិសេធត្រឹមតែសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតបាន ប្រសិនបើការសម្រេចនោះមានការភាន់ច្រឡំនឹងឆន្ទានុសិទ្ធិរបស់ខ្លួន និងមិនច្បាស់លាស់ ប្រសិនបើការសម្រេចនេះ "មិនសមហេតុផល និងមិនមានភស្តុតាងគ្រប់គ្រាន់ "។[៨១]

## IX. ឧឡារិករណ៍

### ៤៦. ក- សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពរបស់ជនត្រូវចោទ:

រហូតមកដល់ពេលនេះ អំណះអំណាងរបស់សហចៅក្រមស៊ើបអង្កេត នៅតែរឹងមាំ។ ស្ថានភាពរបស់សង្គមកម្ពុជាបច្ចុប្បន្នដែលមេធាវីការពារជនត្រូវចោទបានបង្ហាញមិនអាចជឿជាក់បានទេ។ ការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ មុនការបោះឆ្នោត ដែលនឹងមកដល់នៅ ខែ កក្កដា នាពេលខាងមុខនេះ បង្ហាញនូវបរិយាកាសតានតឹងនៅក្នុងសង្គម។ យោងតាមរបាយការណ៍អំពីភាពក្រីក្រ ប្រជាពលរដ្ឋកម្ពុជា ៣៥ ភាគរយ រស់នៅដោយទទួលប្រាក់ចំណូលមិនដល់ ៥០ សេន ដុល្លាអាមេរិចផងក្នុងមួយថ្ងៃ (ដែលនេះនៅឆ្ងាយពីបន្ទាត់ភាពក្រីក្រ ដែលគេព្រមព្រៀងជាអន្តរជាតិ គឺស្មើនឹង១ ដុល្លាអាមេរិចក្នុងមួយថ្ងៃ) ហើយលើសពីនេះទៀតបញ្ហាពុករលួយ គឺនៅតែជាជំងឺរ៉ាំរ៉ៃនៅឡើយ។[៨២]

---

[៨០] សំណុំរឿងរបស់ អៀង ធីរិទ្ធិ លេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស(អ.ប.ជ០២) ការដាក់សារណារួមគ្នារបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ឆ្លើយតបការប្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងដីកាឃុំខ្លួនបណ្តោះអាសន្ន.ERN០០១៨១២៩៧-០០១៨១៣១០. ឯកសារតុលាការលេខ: C ២០/I/១៧. កថាខណ្ឌលេខ ៦-១៣

[៨១] ព្រះរាជអាជ្ញាប្រឆាំងនឹង Moinina Fofana សំណុំរឿងលេខ: SCSL-០៤-១៤- AR៦៥ បណ្តឹងឧទ្ធរណ៍ប្រឆាំងការបដិសេធការធានាខ្លួន នៅថ្ងៃទី ១ មិនា ២០០៥ កថាខណ្ឌ ២០

[៨២] ប្រធានធនាគារពិភពលោកជំរុញឱ្យកម្ពុជាចាត់វិធានការប្រឆាំងអំពើពុករលួយ International Herald Tribune ថ្ងៃទី ៥ សីហា ២០០៧

គេអាចសន្និដ្ឋាន និងយល់ជារួមថាសង្គមកម្ពុជានៅតែមានលក្ខណៈផុយស្រួយនៅឡើយ។ ប្រជាពលរដ្ឋកម្ពុជាអាចមានទំនុកចិត្តលើដំណើរការយុត្តិធម៌ និងនីតិវិធីនេះយ៉ាងដូចម្តេច បើសូម្បីតែនាយករដ្ឋមន្ត្រីដែលធ្លាប់បំរើការងារនៅក្នុងរបបខ្មែរក្រហមបានលើកឡើងថា" ការកាត់ទោសអៀង សារី អាចនាំឱ្យមានសង្គ្រាម"។[៨៣] រឿងនេះកើតឡើងប៉ុន្មានថ្ងៃបន្ទាប់ពីរដ្ឋសភាជាតិអនុម័តជាឯកច្ឆន្ទនូវសេចក្តីព្រាងច្បាប់បង្កើតសាលាជំរះក្តីដែលមានជំនួយពីអង្គការសហប្រជាជាតិ។

អង្គបុរេជំនុំជម្រះបានធ្វើការកត់សម្គាល់យ៉ាងត្រឹមត្រូវនៅក្នុងសេចក្តីសម្រេចបណ្តឹងឧទ្ធរណ៍របស់ នួន ជា[៨៤] ថានេះជាប្រយោជន៍ដ៏ធំធេងមួយនៅក្នុងសវនាការ សាធារណៈជនអាចមានការខឹងសម្បារនឹង ឌុច (ឬក៏ជនត្រូវចោទផ្សេងទៀត) តើវាអាចប៉ះពាល់ដូចម្តេចខ្លះចំពោះសង្គមកម្ពុជា ប្រសិនបើគេដោះលែងជនត្រូវចោទ។[៨៥]

ជាក់ស្តែង ការកត់សម្គាល់របស់សហចៅក្រមស៊ើបអង្កេត ដែលថាការដោះលែងនិងធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងការប្រថុយគ្រោះថ្នាក់ដល់សុវត្ថិភាពរបស់ជនត្រូវចោទនឹងកើតមានចំណែកឯឆន្ទានុសិទ្ធិការរំលោភបំពានលើឆន្ទានុសិទ្ធិរបស់ចៅក្រមស៊ើបអង្កេតឥតមានទេ។

**ខ- ការគំរាមកំហែងសាក្សី**

ដីការបស់សហចៅក្រមស៊ើបអង្កេតមានភាពត្រឹមត្រូវ និងសមហេតុផល។ ដោយសារតែជនត្រូវចោទមានសិទ្ធិពេញលេញក្នុងការមើលសំណុំរឿង ដូចនេះជនត្រូវចោទអាចដឹង ចំលើយ ឈ្មោះ និងអាសយដ្ឋានរបស់សាក្សី។ វាជាការប្រថុយប្រថានដ៏គ្រោះថ្នាក់បំផុតដោយសារជនត្រូវចោទអាចប្រើប្រាស់ឥទ្ធិពលរបស់ខ្លួន ឬតាមរយៈតតិយជនផ្សេងៗគំរាមកំហែងសាក្សីកុំឱ្យផ្តល់សក្ខីភាព។

ការសម្រេចនេះបង្ហាញថាចៅក្រមមិនបានរំលោភឆន្ទានុសិទ្ធិទេ។ លើសពីនេះទៀត ដូចដែលអង្គបុរេជំនុំជម្រះបានបង្ហាញថាមានបរិយាកាសភយ័ខ្លាចក្នុងការផ្តល់សក្ខីភាព។[៨៦] ឥទ្ធិពល និងអំណាចដ៏ទូលំទូលាយរបស់ជនត្រូវចោទ គឺនៅតែមានរហូតមកដល់សព្វថ្ងៃនេះ។

---

[៨៣] "ការកាត់ទោស អៀង សារីអាចនាំឱ្យមានសង្គ្រាម ហ៊ុន សែន" ព័ត៌មាននយោបាយអាស៊ី ថ្ងៃទី១៩ សីហា ឆ្នាំ២០០៧

[៨៤] សំណុំរឿង នួន ជា លេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០១) ERN ០០១៧២៩០៧-០០១៧២៩៣៤ ឯកសារតុលាការលេខ: C១/I/៥៤ សេចក្តីសម្រេចស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាឃុំខ្លួនបណ្តោះអាសន្នរបស់ នួន ជា

[៨៥] សូមមើលកំណត់ត្រា Supra លេខ៧៩ កថាខណ្ឌ៧១.៧៤ និង៧៧-៨១

[៨៦] សូមមើលកំណត់ត្រា Supra លេខ៧៩ កថាខណ្ឌ ៦២ និង៦៣

កាលៈទេសៈនៅពេលដែលគាត់ផ្តាច់ខ្លួនក្នុងឆ្នាំ១៩៩៦ និងឥទ្ធិពលរបស់ជនត្រូវចោទក្នុងជួរកងកម្លាំងខ្មែរក្រហមអាចបង្ហាញបានពីអំណាចរបស់គាត់។

សកម្មភាពជាច្រើនដូចជាការធ្វើទស្សនកិច្ចជាទៀងទាត់ទៅក្រុងប៉ៃលិន ដើម្បីចូលរួមប្រជុំជាមួយមន្ត្រីរដ្ឋាភិបាលចំនួន ៣០ នាក់ ដើម្បីប្រាប់ឱ្យពួកគេកុំពាក់ពន្ធ័ជាមួយកងកម្លាំង[៨៧] បង្ហាញពីអំណាចរបស់គាត់។

**(គ). ភាពប្រថុយប្រថាននៃការរត់គេចខ្លួន**

ការជំទាស់របស់មេធាវីការពារជនត្រូវចោទ ក្នុងករណីនេះ មិនបានបង្ហាញមូលហេតុដើម្បីឱ្យមានការបដិសេធដីកាឃុំខ្លួនរបស់សហចៅក្រមស៊ើបអង្កេតនោះទេ។ ការគាំទ្រលើជនត្រូវចោទនៅក្រុងប៉ៃលិន ការកាន់លិខិតឆ្លងដែន និងការដាក់គុកមួយជីវិត ក្នុងករណីបើជនត្រូវចោទត្រូវបានផ្តន្ទាទោស គឺជាហេតុផលសមស្របធ្វើឱ្យជនត្រូវចោទពិចារណាអំពីការរត់គេចខ្លួន។

ការលើកឡើងថាជនត្រូវចោទមិនបានគេចខ្លួន បើទោះបីជាគាត់ដឹងថាមានការបង្កើតសាលាក្តីខ្មែរក្រហម គឺមិនមែនជាហេតុផលសំខាន់នោះទេ។ ជនត្រូវចោទទទួលបានការលើកលែងទោស និងការលើកលែងទោសទូទៅពីព្រះមហាក្សត្រ និងការគាំទ្រពីប្រមុខរដ្ឋាភិបាលដែលធ្លាប់ធ្វើអត្ថាធិប្បាយថា អៀង សារី នឹងមិនត្រូវនាំមកកាត់ទោសទេ ដោយផ្អែកទៅលើតួនាទីដ៏សំខាន់របស់គាត់ក្នុងការផ្តួចផ្តើមបង្កើតសន្តិភាព និងការផ្សះផ្សារជាតិ។[៨៨]

តាមស្ថានភាពបែបនេះ គេមិនរំពឹងថាជនត្រូវចោទនឹងត្រូវគេឃុំខ្លួននោះទេ។

**(ឃ) - ស្ថានភាពសុខភាព**

ជនត្រូវចោទទទួលបានការពិនិត្យសុខភាពជាទៀងទាត់។ ការឃុំខ្លួន គឺសមស្របមិនបានប៉ះពាល់ដល់សុខភាពទេ។

## X- សន្និដ្ឋាន

៤៨. គេត្រូវតែបដិសេធបណ្តឹងឧទ្ធរណ៍ចោល។ ដីកាឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត គឺសមហេតុផលមានមូលហេតុគ្រប់គ្រាន់ ហើយឆន្ទានុសិទ្ធិនេះត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវ។

---

[៨៧] "អៀង សារី ពេញចិត្តតួនាទីជាអ្នកផ្សះផ្សារនៅក្នុងប្រទេសកម្ពុជា" សារពត៌មាននយោបាយអាស៊ី ថ្ងៃទី ២៩ ធ្នូ ឆ្នាំ២០០០

[៨៨] សូមមើលកំណត់ត្រា Supra លេខ៧៩ កថាខណ្ឌ ៨២

គោលការណ៍នៃការជំនុំជម្រះតែមួយលើកនេះមិនអាចអនុវត្តបានទេនៅក្នុងសំណុំរឿងនេះទេ។ ការលើកលែងទោស និងការលើកលែងទោសទូទៅរបស់ព្រះមហាក្សត្រឆ្នាំ ១៩៩៦ មិនត្រឹមត្រូវតាមច្បាប់ទេ ដូច្នេះវាមិនចងកាតព្វកិច្ចនៅចំពោះមុខ អ.វ.ត.ក នោះឡើយ។

**យោងតាមហេតុផលទាំងនេះ :**

**សូមអង្គបុរេជំនុំជម្រះមេត្តាសម្រេចថា**

- គោលការណ៍នៃជំនុំជម្រះទោសតែមួយលើក ដែលយោងការជំនុំជម្រះឆ្នាំ១៩៧៩ មិនអាចរារាំងការកាត់ទោស និងនីតិវិធីដែលកំពុងតែបន្តនៅចំពោះមុខ អ.វ.ត.ក នោះទេ។
- ការលើកលែងទោស និងការលើកលែងទោសទូទៅ គឺមិនមានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយមិន ចងកាតព្វកិច្ចនៅចំពោះមុខ អ.វ.ត.ក នោះទេ។
- បដិសេធបណ្ដឹងឧទ្ធរណ៍របស់មេធាវីការពារជនត្រូវចោទចោលជាអសារបង់។

**សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

| | |
|---|---|
| លោក ហុង គឹមសួន<br>មេធាវីមកពី ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា | លោក គង់ ពិសី<br>មេធាវីមកពី ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា |
| លោក ឡោ ជុនធី<br>មេធាវីមកពី អង្គការជំនួយ ផ្នែកច្បាប់ នៃកម្ពុជា | លោក នី ចាន់ឌី<br>មេធាវីមកពី អង្គការជំនួយ ផ្នែកច្បាប់ នៃកម្ពុជា |

លោកស្រី Silke Studzinsky

ធ្វើនៅភ្នំពេញ, The Hague ថ្ងៃទី ១៩ ឧសភា ឆ្នាំ២00៨